**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៤៥៦១ **អយក.**៣៦

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ៖** ការផ្តល់ជូនរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២៣។

**យោង៖** ប្រកាសលេខ១១៣ សហវ.ប្រក ចុះថ្ងៃពុធ ១កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំ ស្តីពីការពិនិត្យតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ ដូចមានរបាយការណ៍ និងឧបសម្ព័ន្ធជូនភ្ជាប់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើខ្ញុំ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២៣
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- ខុទ្ទកាល័យ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី «ដើម្បីជូនជ្រាបជាព័ត៌មាន»
- កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍សមិទ្ធកម្ម

## ត្រីមាសទី២

កក្កដា ឆ្នាំ២០២៣

| មាតិកា | ទំព័រ |
| --- | --- |
| **១. សេចក្តីផ្តើម** | ១ |
| **២. វឌ្ឍនភាពនៃការអនុវត្តផែនការ ប្រចាំត្រីមាសទី២** | ១ |
| ២.១. វឌ្ឍភាពនៃការអនុវត្តសកម្មភាពផែនការប្រតិបត្តិប្រចាំឆ្នាំ ប្រចាំត្រីមាសទី២ | ១ |
| ២.២ វឌ្ឍនភាពនៃការអនុវត្តថវិកាផែនការប្រតិបត្តិប្រចាំឆ្នាំ ប្រចាំត្រីមាសទី២ | ២ |
| ២.៣ វឌ្ឍនភាពនៃការសម្រេចបានសូចនាករតាមកម្មវិធី និងអនុកម្មវិធី | ៣ |
| **៣.វឌ្ឍនភាពនៃការអនុវត្តតាមកម្មវិធី** | ១៤ |
| **៣.១ កម្មវិធីទី១៖ ការអភិវឌ្ឍអប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ** | ១៤ |
| ៣.១.១ ការអប់រំកុមារតូច | ១៤ |
| ៣.១.២ ការអប់រំបឋមសិក្សា | ១៤ |
| ៣.១.៣ ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស | ១៤ |
| ៣.១.៤ ការពង្រីកការអប់រំក្រៅប្រព័ន្ធ | ១៤ |
| ៣.១.៥ ការពង្រឹង និងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា | ១៥ |
| ៣.១.៦ ការលើកកម្ពស់ការអនុវត្តកម្មវិធីអប់រំបច្ចេកទេស | ១៥ |
| ៣.១.៧ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន | ១៦ |
| ៣.១.៨ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារសិក្សា និងបណ្ណាល័យ | ១៦ |
| ៣.១.៩ ការពង្រីកការអប់រំបរិយាបន្នគ្រប់កម្រិតសិក្សា | ១៦ |
| ៣.១.១០ ការងារវិទ្យាស្ថានជាតិអប់រំពិសេស | ១៧ |
| **៣.២ កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ** | ១៧ |
| ៣.២.១ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | ១៧ |
| ៣.២.២ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា | ១៨ |
| ៣.២.៣ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ១៨ |
| ៣.២.៤ សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ | ១៨ |
| ៣.២.៥ សាកលវិទ្យាល័យជាតិ ជា ស៊ីម កំចាយមារ | ១៨ |
| ៣.២.៦ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ១៩ |
| ៣.២.៧ វិទ្យាស្ថានជាតិអប់រំ | ១៩ |
| ៣.២.៨ សាកលវិទ្យាល័យស្វាយរៀង | ១៩ |
| ៣.២.៩សាកលវិទ្យាល័យជាតិមានជ័យ | ១៩ |
| ៣.២.១០ សាកលវិទ្យាល័យជាតិបាត់ដំបង | ២០ |
| ៣.២.១១ ការទទួលស្គាល់គុណភាពអប់រំ | ២០ |
| ៣.២.១២ វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | ២០ |
| ៣.២.១៣ សាកលវិទ្យាល័យក្រចេះ | ២០ |
| ៣.២.១៤ វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | ២០ |
| ៣.២.១៥ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | ២០ |
| ៣.២.១៦ វិទ្យាស្ថានគរុកោសល្យបាត់ដំបង | ២១ |
| **៣.៣ កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា** | ២២ |
| ៣.៣.១ ការងារវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | ២២ |
| ៣.៣.២ ការងារអប់រំកាយ និងកីឡា | ២២ |
| ៣.៣.៣ ការងារអប់រំកាយ និងកីឡាសិស្ស និស្សិត | ២៣ |
| ៣.៣.៤ ការងារហ្វឹកហ្វឺនកីឡា | ២៣ |

| | |
|---|---|
| ៣.៣.៥ ការងាររៀបចំ និងគ្រប់គ្រងព្រឹត្តិការណ៍កីឡា | ២៣ |
| ៣.៣.៦ ការងារមជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យា និងស្ថិតិកីឡា | ២៣ |
| **៣.៤ កម្មវិធីទី៤៖ ការអភិវឌ្ឍជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់យុវជន** | ២៤ |
| ៣.៤.១ ការពង្រឹងសកម្មភាពយុវជន | ២៤ |
| ៣.៤.២ ការអភិវឌ្ឍគ្រប់គ្រងមជ្ឈមណ្ឌល | ២៤ |
| ៣.៤.៣ ការអភិវឌ្ឍកាយវប្បកម្មជា | ២៥ |
| **៣.៥ កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ** | ២៥ |
| ៣.៥.១ ការអភិវឌ្ឍគោលនយោបាយនិងពង្រឹងប្រព័ន្ធផែនការអប់រំ | ២៥ |
| ៣.៥.២ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស | ២៦ |
| ៣.៥.៣  ការអភិវឌ្ឍសមត្ថភាពគ្រប់គ្រងផែនការហិរញ្ញវត្ថុ និងមូលដ្ឋានសម្ភារៈ | ២៦ |
| ៣.៥.៤ ការងារសវនកម្មផ្ទៃក្នុង | ២៧ |
| ៣.៥.៥ ការងារធានាគុណភាពអប់រំ | ២៧ |
| ៣.៥.៦ ការងារអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | ២៨ |
| ៣.៥.៧ ការងារព័ត៌មាន និងកិច្ចការអាស៊ាន | ២៨ |
| ៣.៥.៨ ការងារនីតិកម្ម | ២៩ |
| ៣.៥.៩ ការងារសំណង់សិក្សា | ២៩ |
| ៣.៥.១០  ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | ២៩ |
| ៣.៥.១១ ការគ្រប់គ្រងរដ្ឋបាល | ៣០ |
| ៣.៥.១២ ការងារទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | ៣០ |
| ៣.៥.១៣ ការងារប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | ៣០ |
| ៣.៥.១៤  ការស្រាវជ្រាវនិងអភិវឌ្ឍគោលនយោបាយអប់រំ | ៣១ |
| ៣.៥.១៥  ការងារពិនិត្យតាមដាន និងវាយតម្លៃ | ៣១ |
| ៣.៥.១៦  ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន | ៣១ |
| ៣.៥.១៧ ការងារកិច្ចការប្រឡង | ៣២ |
| ៣.៥.១៨ ការងារមជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស | ៣២ |
| **៤. សេចក្តីសន្និដ្ឋាន** | ៣៣ |

## ១. សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ រៀបចំឡើងឆ្លើយតបគោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបន្សុីទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ព្រមទាំងបានដាក់ចេញនូវវិធានការកែលម្អការគ្រប់គ្រងថវិកាឱ្យមានប្រសិទ្ធភាព ក្នុងការផ្សារភ្ជាប់រវាងលទ្ធផល និងធនធានហិរញ្ញវត្ថុ ការកសាងសមត្ថភាពក្នុងការធ្វើផែនការថវិកាផ្អែកលើលទ្ធផល ការដំណើរការប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការរៀបចំថវិការបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការកែលម្អស្វ័យភាពនៃដំណើរការគណនេយ្យ និងការរៀបចំរបាយការណ៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការពិនិត្យតាមដាន ជាទៀងទាត់នូវផលសម្រេចរបស់អនុវិស័យ និងឆ្លងអនុវិស័យនីមួយៗ ផ្អែកលើគណនេយ្យភាពថវិកាសមិទ្ធកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

របាយការណ៍សមិទ្ធកម្មត្រីមាសទី២ ឆ្នាំ២០២៣ ឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាដោយផ្អែកលើក្របខណ្ឌសសរស្តម្ភទាំង៥ ដែលឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយជំហានទី២ (២០២២-២០២៥)។ របាយការណ៍នេះមានវត្ថុបំណងពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២៣ តាមរយៈសកម្មភាពបានលើកឡើងក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកា ក្នុងគោលដៅបង្កើនប្រសិទ្ធភាព ផលិតភាព និងសមិទ្ធផល អនុលោមទៅតាមលទ្ធភាពធនធាន បង្កើនគណនេយ្យភាព និងតម្លាភាព នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្នុងការពង្រឹង និងបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃការអនុវត្តថវិកាកម្មវិធី។ របាយការណ៍នេះក៏បានបង្ហាញអំពីសមិទ្ធផលសម្រេចបានរបស់កម្មវិធី និងអនុកម្មវិធីនីមួយៗ ព្រមទាំងបញ្ហាប្រឈមជារួមរបស់ក្រសួងផងដែរ។

## ២.វឌ្ឍនភាពនៃការអនុវត្តផែនការ ប្រចាំត្រីមាសទី២

### ២.១ វឌ្ឍភាពនៃការអនុវត្តសកម្មភាពផែនការប្រតបត្តប្រចាំឆ្នាំ ប្រចាំត្រមាសទី២

ឆ្នាំ២០២៣នេះ គ្រប់អង្គភាពបានគ្រោងសកម្មភាពក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣ ប្រចាំត្រីមាសទី២ ចំនួន ៦១៨ សកម្មភាព ក្នុងនោះអនុវត្តចប់ចំនួន១១៨ ស្មើ ១៩,០៩ភាគរយ កំពុងអនុវត្តចំនួន៣៦៧ ស្មើ ៥៩,៣៩ ភាគរយ និងមិនបានអនុវត្តចំនួន ១៣៣ ស្មើ ២១,៥២ភាគរយ។

**រូបភាពទី១៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពប្រចាំត្រីមាសទី២**



ការគ្រោងសកម្មភាពអនុវត្តប្រចាំត្រីមាសទី២ តាមចង្កោមសកម្មភាពទី១ ចំនួន ៣៨០សកម្មភាព និងចង្កោមសកម្មភាពទី២ ចំនួន ២៣៨សកម្មភាព ។ ចង្កោមសកម្មភាព ទី១ អនុវត្តចប់ចំនួន ៧៣ ស្មើ ១៩,២១ភាគរយ កំពុងអនុវត្តចំនួន ២៤៧ ស្មើ ៦៥ភាគរយ និងមិនបានអនុវត្តចំនួន ៦០ ស្មើ ១៥,៧៩ភាគរយ។ ចង្កោមសកម្មភាពទី២ អនុវត្តចប់ចំនួន ៤៥ ស្មើ ១៨,៩១ភាគរយ កំពុងអនុវត្តចំនួន ១២០ ស្មើ ៥០,៤២ភាគរយ និងមិនបានអនុវត្តចំនួន ៧៣ ស្មើ ៣០,៦៧ភាគរយ។

**រូបភាពទី២៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាព តាមចង្កោមសកម្មភាព**




## ២.២ វឌ្ឍនភាពនៃការអនុវត្តថវិកាផែនការប្រតិបត្តិប្រចាំឆ្នាំ ប្រចាំត្រីមាសទី២

ថវិកាសរុបរបស់ក្រសួងចំនួន **៣ ៣៦១ ៨២៥,៦ លានរៀល អនុវត្តបាន១ ៤៤៩ ៨១៥,៥ លានរៀល ស្មើ ៤៣,០០ ភាគរយ ក្នុងនោះ**រដ្ឋបាលកណ្តាលចំនួន ៣៧៧ ៤៧៨ ៦០០ ០០០ រៀល **អនុវត្តបាន ១៤៣ ៨៨៤ ២៩០ ៥៦៨** រៀល ស្មើ ៣៨,១២ភាគរយ រាជធានី ខេត្តចំនួន ២ ៩៨៤ ៣៤៧ ០០០ ០០០ រៀល អនុវត្តបាន ១ ៣០៥ ៩៣០ ២៤០ ៤៥២រៀល ស្មើ ៤៣,៧៦ ភាគរយ។ **កម្មវិធីទី១** ចំនួន ៦២ ៨៩០ ៨០០ ០០០ រៀល អនុវត្តបាន ១៨ ៩៧១ ៧៧២ ១៥២រៀល ស្មើ ៣០,១៧ភាគរយ **កម្មវិធីទី២** ចំនួន ៣៣ ៣៤៨ ៩០០ ០០០រៀល អនុវត្តបាន ១៥ ៧៤២ ៨៦៧ ២០០រៀល ស្មើ ៤៧,២១ភាគរយ **កម្មវិធីទី៣** ចំនួន ៤៣ ៨៧៣ ៧០០ ០០០រៀល អនុវត្តបាន ១៧ ៥៦៦ ០៣៣ ៩៤៨រៀល ស្មើ ៤០,០៤ភាគរយ **កម្មវិធីទី៤** ចំនួន ៩ ០០៧ ៧០០ ០០០រៀល អនុវត្តបាន ៤ ៣១៥ ៥៨៩ ៨០០រៀល ស្មើ៤៧,៩១ភាគរយ និង**កម្មវិធីទី៥** ចំនួន ២២៨ ៣៥៧ ៥០០ ០០០រៀល អនុវត្តបាន ៨៧ ២៨៨ ០២៧ ៤៦៨ រៀល ស្មើ ៣៨,២២ភាគរយ។

**រូបភាពទី៣៖ វឌ្ឍនភាពនៃការអនុវត្តថវិកា ប្រចាំត្រីមាសទី២**



## ២.៣ វឌ្ឍនភាពនៃការសម្រេចបានសូចនាករតាមកម្មវិធី និងអនុកម្មវិធីប្រចាំត្រីមាសទី២

ការកំណត់សូចនាករតាមកម្មវិធីទាំង៥ សរុប ១១ សូចនាករ ក្នុងនោះប្រចាំត្រីមាសទី២ សម្រេចចំណុចដៅ ៤ ស្មើ ៣៦,៣៦ភាគរយ អាចទទួលយកបាន ៤ ស្មើ ៣៦,៣៦ភាគរយ និងមិនសម្រេចចំណុចដៅ ៣ ស្មើ ២៧,២៧ភាគរយ។ សូចនាករតាមអនុកម្មវិធីសរុប ១២៩ សូចនាករ ក្នុងនោះប្រចាំត្រីមាសទី២ សម្រេចចំណុចដៅ ៤១ ស្មើ ៣១,៧៨ ភាគរយ អាចទទួលយកបាន ៥៦ ស្មើ ៤៣,៤១ភាគរយ និងមិនសម្រេចចំណុចដៅ ៣២ ស្មើ ២៤,៨១ភាគរយ។

**រូបភាពទី៤ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករកម្មវិធី អនុកម្មវិធី**




**បើពិនិត្យតាមកម្មវិធីទាំង ៥ មាន៖**

***កម្មវិធីទី១ "ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ"*** សរុប ៤សូចនាករ សម្រេចចំណុចដៅ ២ ស្មើ ៥០ភាគរយ អាចទទួលយកបាន ២ ស្មើ ៥០ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។ កម្មវិធីទី១ មានអនុកម្មវិធី ១០ សរុប ២២សូចនាករ សម្រេចចំណុចដៅ ១២ ស្មើ ៥៤,៥៥ភាគរយ អាចទទួលយកបាន ៥ ស្មើ ២២,៧៣ភាគរយ និងមិនបានអនុវត្ត ៥ ស្មើ ២២,៧៣ភាគរយ។ លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី១

- អត្រាចូលរៀនកុមារអាយុ៥ឆ្នាំគ្រប់រូបភាពចំណុចដៅ ៦៣.១% សម្រេចបាន ៦៤.៨%
- អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាចំណុចដៅ ៨៨.៧%សម្រេចបាន ៨៦.៨%
- អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ចំណុចដៅ ៥៣.១% សម្រេចបាន ៥៥.៧%
- អត្រាអក្ខរកម្មពេញវ័យ (អាយុ១៥ ឆ្នាំឡើង) ចំណុចដៅ ៩០.៧% សម្រេចបាន ៨៤.៧%

**ការសម្រេចបានសូចនាករតាមអនុកម្មវិធី**

អនុកម្មវិធី១.១៖ ការពង្រីកការអប់រំកុមារតូច (នាយកដ្ឋានអប់រំកុមារតូច)

- អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំនៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងឯកជន ចំណុចដៅ ៦៣.១% សម្រេចបាន ៦៤.៨%
- អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាឯកជន ចំណុចដៅ ៣៧.៤% សម្រេចបាន ៣៧.១%

អនុកម្មវិធី១.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា (នាយកដ្ឋានអប់រំបឋមសិក្សា)

- អត្រាពិតនៃការសិក្សា ចំណុចដៅ ៩៣% សម្រេចបាន ៩៣%
- អត្រាត្រួតថ្នាក់ ចំណុចដៅ ៥% សម្រេចបាន ៧%
- អត្រាបោះបង់ការសិក្សា ចំណុចដៅ ៦% សម្រេចបាន ៧%

អនុកម្មវិធី១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ នៅមធ្យមសិក្សា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ)

- អត្រាត្រួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ចំណុចដៅ ៧០.៤% សម្រេចបាន ៦៤.៨%
- អត្រាត្រួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ចំណុចដៅ ៣៨.៦% សម្រេចបាន ៤៤.២%
- អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិចំណុចដៅ ៨៤.៧% សម្រេចបាន ៨៣.៧%
- អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ចំណុចដៅ ៥៣.១% សម្រេចបាន ៥៥.៧%
- អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ចំណុចដៅ ១៤.១% សម្រេចបាន ១៧.២%

អនុកម្មវិធី១.៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ (នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ)

- ប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម ចំណុចដៅ ១២ ៦០០ នាក់" សម្រេចបាន ១ ៥៥០០នាក់"
- សិស្សបានបញ្ចប់ថ្នាក់កម្មវិធីសមមូល ចំណុចដៅ ៧ ៤៨៧ នាក់ សម្រេចបាន ៣១០០នាក់"
- ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញនិងបានបញ្ជូនទៅក្នុងប្រព័ន្ធ ចំណុចដៅ ១០ ៤០០ នាក់ សម្រេចបាន ០ នាក់
- ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាល ជំនាញមុខរបរសម្រាប់ការសិក្សាពេញមួយជីវិត (ម.ស.ស)ចំណុចដៅ "៩៤៩០ នាក់ សម្រេចបាន ៩ ៥០០នាក់"
- ចំនួនមន្ត្រីអកបទទួលការបណ្តុះបណ្តាលសមត្ថភាពការគ្រប់គ្រងលើសេវាអកប ចំណុចដៅ ១៩០ នាក់ សម្រេចបាន ០ នាក់

អនុកម្មវិធី១.៥៖ ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា(នាយកដ្ឋានសុខភាពសិក្សា)

- ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ១ (ចំណាត់ថ្នាក់ផ្កាយ ១) ចំណុចដៅ ៣៤% សម្រេចបាន ០
- ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ២ (ចំណាត់ថ្នាក់ផ្កាយ ២)" ចំណុចដៅ ៤៥% សម្រេចបាន ០
- ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ៣ (ចំណាត់ថ្នាក់ផ្កាយ៣) ចំណុចដៅ ៥% សម្រេចបាន០
- ភាគរយសាលារៀនមានបង្គន់អនាម័យ ចំណុចដៅ ១០០% សម្រេចបាន ០
- ភាគរយសាលារៀនមានទឹកស្អាត ចំណុចដៅ ៨៥% សម្រេចបាន ០
- ភាគរយសាលារៀនមានកន្លែងលាងសម្អាតដៃ ចំណុចដៅ ៨៥% សម្រេចបាន ០
- ភាគរយសាលារៀនមានប្រអប់សង្គ្រោះបឋម ចំណុចដៅ ៤៥% សម្រេចបាន០

អនុកម្មវិធី១.៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស (នា.តទវ)

ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ចំណុចដៅ ១៩ សាលា សម្រេចបាន ១៩ សាលា

អនុកម្មវិធី១.៧៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន (នា.បវ)

- ចំនួនគរុសិស្ស គរុនិស្សិតបានទទួលការបណ្តុះបណ្តាល នៅសាលាគរុកោសល្យ ចំណុចដៅ ៣០០០ សម្រេចបាន ២៧០៧
- ចំនួនមន្ត្រីគ្រប់គ្រងអប់រំ និងនាយក នាយករង គ្រូបង្រៀន បឋមសិក្សាមធ្យមសិក្សាចំណេះទូទៅបានទទួលការលើកកម្ពស់សមត្ថភាពចំណុចដៅ ៣៥១ សម្រេចបាន ២៥០

- ចំនួនគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាបានតំឡើង គុណវុឌ្ឍិទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំណុចដៅ ១៥០០ សម្រេចបាន ០

អនុកម្មវិធី១.៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា)

- ចំនួនសៀវភៅសិក្សាគោលត្រូវបានផ្គត់ផ្គង់សម្រាប់សិស្សថ្នាក់ទី១ដល់ទី១២ ចំណុចដៅ ៥ ២៧៦ ០០០ ច្បាប់" សម្រេចបាន ៥ ៣៥៣ ០០០ ច្បាប់"
- ចំនួនសិស្សចូលរួមប្រកួតតែងនិពន្ធ សូត្រកំណាព្យនិងសម្តែងសិល្បៈក្នុងទិវាជាតិអំណាន ១១មីនា ចំណុចដៅ ៧៥ នាក់ សម្រេចបាន ៧៥ នាក់

"អនុកម្មវិធី១.៩៖ ពង្រីកការអប់រំបរិយាបន្នគ្រប់កម្រិតសិក្សា(នាយកដ្ឋានអប់រំពិសេស)"

- ចំនួនគ្រូបង្រៀនថ្នាក់អប់រំពហុភាសាសម្រាប់បឋមសិក្សា ចំណុចដៅ ២៤២ សម្រេចបាន ២៣៥
- ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ បានកសាងសមត្ថភាពស្តីពីការអប់រំបរិយាបន្ន និងអប់រំពិសេស ចំណុចដៅ ១២០ សម្រេចបាន ១២០
- ចំនួនសិស្សមានពិការភាព(គ ថ្លង់ ពិការភ្នែក និងសតិបញ្ញា...) ដែលបានរៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម ចំណុចដៅ ១០០៣ សម្រេចបាន ១០៥៩

***កម្មវិធីទី២ "ការអភិវឌ្ឍឧត្តមសិក្សានិងការស្រាវជ្រាវ"*** សរុប ២ សូចនាករសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ មិនសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ។ កម្មវិធីទី២ មានអនុកម្មវិធី ១៨ សរុប ៤៦ សូចនាករ សម្រេចចំណុចដៅ ២២ ស្មើ ៤៧,៨៣ភាគរយ អាចទទួលយកបាន ២០ ស្មើ ៤៣,៤៨ភាគរយ និងមិនសម្រេចចំណុចដៅ ៤ ស្មើ ៨,៧០ភាគរយ។ លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី២

- អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២)" ចំណុចដៅ ១៥.៧% សម្រេចបាន ១៤.៩%
- ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលស្នែម ចំណុចដៅ ៣៣.២% សម្រេចបាន ២៥.៦%

**ការសម្រេចបានសូចនាករតាមអនុកម្មវិធី**

អនុកម្មវិធី២.១៖ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា(នាយកដ្ឋានឧត្តមសិក្សា)

- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងចំណុចដៅ ២៥ សម្រេចបាន ២១
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានរៀបចំ និងអនុវត្តការគាំទ្ររបស់និស្សិតចំណុចដៅ ១៦ សម្រេចបាន ២៤
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានធ្វើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់សិក្សាចំណុចដៅ ១០ សម្រេចបាន ២២
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យឧត្តមសិក្សាចំណុចដៅ ៣៣ សម្រេចបាន ៤៩
- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រចំណុចដៅ ៦ សម្រេចបាន ៦

អនុកម្មវិធី២.២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា (នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ)

- ភាគរយនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយការសរសេររបាយការណ៍ស្រាវជ្រាវសរសេរ ឬនិក្ខេបបទធៀបនឹងនិស្សិតបញ្ចប់ក្នុងឆ្នាំ ចំណុចដៅ ១៤% សម្រេចបាន ០
- ចំនួនគ្រឹះស្ថានដែលរៀបចំ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រចំណុចដៅ ១០ គ្រឹះស្ថាន សម្រេចបាន ០

- ចំនួនបុគ្គលិកបង្រៀន មន្ត្រីជំនាញ និងនិស្សិតដែលចូលរួមអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវ និងនវានុវត្តន៍ចំណុចដៅ ៣៧ នាក់ សម្រេចបាន ០

អនុកម្មវិធី២.៣៖ ការពង្រឹងគុណភាពអប់រំ និងស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព( សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)

- ភាគរយនិស្សិតអាហារូបករណ៍និងបង់ថ្លៃ(ឆ្នាំទី៤)ប្រឡងជាប់បរិញ្ញាបត្រចំណុចដៅ ៩៥% សម្រេចបាន ៩៥%

អនុកម្មវិធី២.៤៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំ បណ្តុះបណ្តាលនិងស្រាវជ្រាវប្រកបដោយ ប្រសិទ្ធភាព (សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ)"

- ចំនួនសិស្សនិស្សិតចូលរៀនបរិញ្ញាបត្រ បរិញ្ញាបត្ររង និងគុណវុឌ្ឍិ១ ២ ៣ ទាំងអាហារូបករណ៍ និងមិនមែនអាហារូបករណ៍ត្រូវបានបង្កើនចំណុចដៅ ២ ៤៤០ នាក់ សម្រេចបាន ០

អនុកម្មវិធី២.៥៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ (សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ )"

- ភាគរយនិស្សិតដែលបញ្ចប់ការសិក្សាទទួលបានការងារធ្វើនៅតាមស្ថាប័ននានា ចំណុចដៅ ៩៥% សម្រេចបាន ៩៦%
- ចំនួនអត្ថបទនៃការសិក្សាស្រាវជ្រាវរបស់គ្រូបុគ្គលិកអប់រំត្រូវបានបោះពុម្ពប្រចាំឆ្នាំ ចំណុចដៅ ៣ អត្ថបទ សម្រេចបាន ០ អត្ថបទ

អនុកម្មវិធី២.៦៖ ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា)

- ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ ឬ បន្តការសិក្សា ចំណុចដៅ ៩០% សម្រេចបាន ០
- ចំនួនប្រធានបទស្រាវជ្រាវសរុបដែលបានបោះពុម្ពផ្សាយ ឬចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ ចំណុចដៅ ៥៥ សម្រេចបាន ១៩៤
- ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត ចំណុចដៅ ២៧.៤%សម្រេចបាន ០.២៧៤

អនុកម្មវិធី ២.៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការណ្តុះបណ្តាល និងស្រាវជ្រាវ (វិទ្យាស្ថានជាតិអប់រំ)

- ចំនួនគរុនិស្សិតកម្រិតឧត្តម(បរិញ្ញា+១)និងគរុសិស្សកម្រិតមូលដ្ឋាន(១២+៤)បានទទួលការបណ្តុះបណ្តាលប្រចាំឆ្នាំ ចំណុចដៅ ៤៤៥ សម្រេចបាន ១៨២
- ចំនួននិស្សិតថ្នាក់បណ្ឌិតបានទទួលការបណ្តុះបណ្តាលតាមឆ្នាំនីមួយៗចំណុចដៅ ៤៩ សម្រេចបាន ៨
- ចំនួននិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិធីសាស្ត្របង្រៀនភាសាបារាំង គ្រប់គ្រងអប់រំ ប្រឹក្សាគរុកោសល្យ វិជ្ជាជីវៈនាយកសាលា អធិការអប់រំ និងគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ១០០៥ សម្រេចបាន ៩០០
- ចំនួនមន្ត្រីគ្រប់គ្រងផែនការថ្នាក់រាជធានីខេត្ត អធិការអប់រំថ្នាក់រាជធានីខេត្ត នាយកវិទ្យាល័យ ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ទទួលបានការបំប៉ន ដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ពួកគាត់ ចំណុចដៅ ១៧៣០ សម្រេចបាន ៨៦៥
- ចំនួនបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំបានទទួលការបំប៉នសមត្ថភាពក្នុងនិងក្រៅប្រទេស ចុះធ្វើការស្រាវជ្រាវពិនិត្យតាមដានវាយតម្លៃលើការអនុវត្តការងាររបស់អតីតគរុនិស្សិត គ្រូបង្រៀន ពិសោធន៍វិទ្យាសាស្ត្រ និងកម្មវិធីបណ្តុះបណ្តាល ចំណុចដៅ ១៥៥ សម្រេចបាន ៧៨

អនុកម្មវិធី២.៨៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ (សាកលវិទ្យាល័យស្វាយរៀង)

- ចំនួននិស្សិតបានបញ្ចប់ការសិក្សា ស្របតាមតម្រូវទីផ្សារការងារ ចំណុចដៅ ៧០០ នាក់ សម្រេចបាន ០
- ចំនួនគម្រោងស្រាវជ្រាវបានផលិតសម្រាប់បម្រើឲ្យការអភិវឌ្ឍ ចំណុចដៅ ៤ គម្រោង សម្រេចបាន ០

អនុកម្មវិធី២.៩៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការ បណ្តុះបណ្តាល និងការស្រាវជ្រាវ (សាកលវិទ្យាល័យជាតិមានជ័យ)"

- ចំនួននិស្សិតចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលវិទ្យាសាស្ត្រ និងសង្គម ចំណុចដៅ ៨០០សម្រេចបាន ៨៧៦
- ចំនួនភាគរយនិស្សិតគ្រប់ជំនាញបញ្ចប់ការសិក្សាមានការងារធ្វើចំណុចដៅ ៨០% សម្រេចបាន ១.២
- ចំនួនកម្មវិធីសិក្សាតាមមុខជំនាញដែលបានកែលម្អដោយផ្តោតលើលទ្ធផលរំពឹងទុកស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ ចំណុចដៅ ២ សម្រេចបាន ៣
- គ្រឹះស្ថានទទួលបានការទទួលស្គាល់គុណភាពអប់រំតាមកម្រិតគ្រឹះស្ថាន ចំណុចដៅ ១០០% សម្រេចបាន ០.៥

អនុកម្មវិធី២.១០៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ (សាកលវិទ្យាល័យជាតិបាត់ដំបង)

- ភាគរយគ្រូបង្រៀនត្រូវបានលើកកម្ពស់គុណវុឌ្ឍិ ចំណុចដៅ បរិ.ខ្ពស់ ៨៧នាក់ បណ្ឌិត ៨នាក់ សម្រេចបាន ៦៦ នាក់
- ភាគរយនិស្សិតមានការងារស្របតាមជំនាញ ចំណុចដៅ ៧៨% សម្រេចបាន ០
- ចំនួនលទ្ធផលសិក្សាស្រាវជ្រាវផ្សារភ្ជាប់នឹងទីផ្សារត្រូវបានផលិត ចំណុចដៅ ៨ សម្រេចបាន ៦

អនុកម្មវិធី២.១៣៖ ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា(គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា)

- ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលទទួលបានការទទួលស្គាល់គុណភាពអប់រំចំណុចដៅ ១០ គ្រឹះស្ថាន សម្រេចបាន ០

អនុកម្មវិធី២.១៤៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវលើផ្នែកបច្ចេកទេស វិជ្ជាជីវៈ និងសេវាសហគមន៍ (វិទ្យាស្ថានកំពង់ឈើទាល)

- ចំនួនសិស្ស និស្សិត គរុសិស្សទទួលបានការបណ្តុះបណ្តាលប្រកបដោយគុណភាព និងបរិយាបន្ន ស្របតាមការអភិវឌ្ឍនៃបច្ចេកវិទ្យា ចំណុចដៅ ១២៥០ សម្រេចបាន ១១៤៧
- ភាគរយបុគ្គលិកសិក្សាគ្រប់រូបមានសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ចំណុចដៅ ១០០% សម្រេចបាន ០.៨៥

អនុកម្មវិធី២.១៥៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ (សាកលវិទ្យាល័យក្រចេះ)

- ចំនួនសិស្ស-និស្សិតចូលរៀនថ្នាក់អប់រំបច្ចេកទេស ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រគ្រប់ជំនាន់ ទាំងអាហារូបករណ៍ និងមិនមែនអាហារូបករណ៍ត្រូវបានបង្កើន ចំណុចដៅ ៤៨០ នាក់ (ស្រី ២៥០ នាក់) សម្រេចបាន ៤២៥ នាក់ (ស្រី ២២៨ នាក់)"
- ចំនួនគម្រោងស្រាវជ្រាវត្រូវបានអនុវត្តក្នុងការលើកកម្ពស់គុណភាពនៃការសិក្សាទាំងកម្រិតអប់រំបច្ចេកទេស បរិញ្ញាបត្ររង និងបរិញ្ញាបត្រឆ្លើយតបទៅតាមតម្រូវការទីផ្សារការងារ ចំណុចដៅ ៥ គម្រោង សម្រេចបាន ២ គម្រោង
- ចំនួនកម្មវិធីសិក្សាថ្នាក់អប់រំបច្ចេកទេស ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បន្តបរិញ្ញាបត្រដែលបានធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្ត ចំណុចដៅ ៨ កម្មវិធី សម្រេចបាន ៥ កម្មវិធី
- ភាគរយបុគ្គលិក និងគ្រូបង្រៀនដែលទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែមជាប្រចាំលើការងារ ដែលខ្លួនទទួលខុស ត្រូវតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានាចំណុចដៅ ៨០% សម្រេចបាន ៤០%

អនុកម្មវិធី២.១៦៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំ និងការស្រាវជ្រាវលើផ្នែកអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ (វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ)

- ចំនួនសិស្ស និស្សិតអាហារូបករណ៍ថ្នាក់អប់រំបច្ចេកទេស និងវិជ្ជាជីវៈ ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រ ត្រូវបានជ្រើសរើសចូលរៀនប្រចាំឆ្នាំ ចំណុចដៅ ១៦០ សម្រេចបាន ១៧៤
- ភាគរយសិស្ស និស្សិតថ្នាក់អប់រំបច្ចេកទេស និងវិជ្ជាជីវៈ ថ្នាក់បរិញ្ញាបត្ររងនិងថ្នាក់បន្តបរិញ្ញាបត្រដែលបានបញ្ចប់ការសិក្សាដោយជោគជ័យចំណុចដៅ ៧៥% សម្រេចបាន ០
- ចំនួនកម្មវិធីសិក្សាថ្នាក់អប់រំបច្ចេកទេស ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បន្តបរិញ្ញាបត្រដែលបានធ្វើបច្ចុប្បន្នភាព និងដាក់ឲ្យអនុវត្ត ចំណុចដៅ ១១ សម្រេចបាន ០
- ភាគបុគ្គលិកការិយាល័យ និងបុគ្គលិកបង្រៀនដែលទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែមប្រចាំឆ្នាំលើការងារដែលខ្លួនទទួលខុសត្រូវចំណុចដៅ ៨០% សម្រេចបាន ០.៤

អនុកម្មវិធី២.១៧៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំគ្រូបង្រៀនឆ្លើយតបតាមលក្ខខណ្ឌ គុណវុឌ្ឍិជាតិ (វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ)

- ចំនួនគរុនិស្សិតបឋមសិក្សាថ្នាក់បរិញ្ញាបត្រអប់រំ(១២+៤) បានទទួលការបណ្តុះបណ្តាលចំណុចដៅ ៤៤៨ សម្រេចបាន ៤៤៨
- ចំនួនគរុនិស្សិតកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ ថ្នាក់បរិញ្ញាបត្រអប់រំ (១២+៤)បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ២៩៨ សម្រេចបាន ២៩៨
- ចំនួនគរុសិស្សកម្រិតមូលដ្ឋាន(១២+២)បានទទួលការបណ្តុះបណ្តាលចំណុចដៅ ២៣ សម្រេចបាន ២៣
- ចំនួនគ្រូបង្រៀនបឋមសិក្សាទទួលបានការបណ្តុះបណ្តាលបង្កើនគុណវុឌ្ឍិជាគ្រូបង្រៀនកម្រិតមូលដ្ឋានចំណុចដៅ ៥៨៦សម្រេចបាន ៥៨៦
- ចំនួនបុគ្គលិកអប់រំ ទទួលបានការអភិវឌ្ឍវិជ្ជាជីវៈ ទាំងនៅក្នុង និងក្រៅប្រទេស ចំណុចដៅ ១៨៤ សម្រេចបាន ១៨៤

អនុកម្មវិធី២.១៨៖ ពង្រឹងគុណភាពបណ្តុះបណ្តាល វិក្រឹតការគ្រូនិងការស្រាវជ្រាវស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ (វិទ្យាស្ថានគរុកោសល្យបាត់ដំបង)

- ចំនួនគរុនិស្សិតបឋមសិក្សាថ្នាក់បរិញ្ញាបត្រអប់រំ (១២+៤) បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ២០២ សម្រេចបាន ២៩៩
- ចំនួនគរុនិស្សិតកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យថ្នាក់បរិញ្ញាបត្រអប់រំ (១២+៤)បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ១៣៤ សម្រេចបាន ១៩៩
- ចំនួនគរុសិស្សបឋមសិក្សា(១២+២)បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ៥៦ សម្រេចបាន ៧០
- ចំនួនគរុសិស្សកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ (១២+២)បានទទួលការបណ្តុះបណ្តាល ចំណុចដៅ ២៣ សម្រេចបាន ២៩
- ចំនួនគ្រូបង្រៀនបឋមសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានទទួលការបំប៉នឱ្យទៅ ជាគ្រូបង្រៀនកម្រិមូលដ្ឋាន ចំណុចដៅ ១៨៨ សម្រេចបាន ៣២៧

***កម្មវិធីទី៣ “ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា”*** សរុប ៣ សូចនាករ សម្រេចចំណុចដៅ ២ ស្មើ ៦៦,៦៧ ភាគរយ អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ ១ ស្មើ ៣៣,៣៣ភាគរយ។ កម្មវិធីទី៣ មានអនុកម្មវិធី ៦ សរុប ៨សូចនាករ សម្រេចចំណុចដៅ ១ ស្មើ ១២,៥០ភាគរយ អាចទទួលយកបាន ៣ ស្មើ ៣៧,៥០ភាគរយ និងមិនសម្រេចចំណុចដៅ ៤ ស្មើ ៥០ភាគរយ។ លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី៣

- ចំនួនមេដាយពីការប្រកួតកីឡាអន្តរជាតិចំណុចដៅ ២៧៤ សម្រេចបាន ២៨២
- ចំនួនមន្ត្រីបច្ចេកទេសកីឡាដែលបានបណ្តុះបណ្តាល ចំណុចដៅ ១០៥០ សម្រេចបាន ១៣០
- ចំនួនប្រជាជនហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាព ចំណុចដៅ ២០.៤% សម្រេចបាន ២០.៤%

**ការសម្រេចបានសូចនាករតាមអនុកម្មវិធី**

អនុកម្មវិធី៣.១៖ ការអភិវឌ្ឍកីឡាមហាជន (នាយកដ្ឋានអប់រំកាយ និងកីឡា)

- ភាគរយមហាជនហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពចំណុចដៅ ២០.៤% សម្រេចបាន ០
- ចំនួនគ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម និងមន្ត្រីរៀបចំការប្រកួតកីឡាបានបណ្តុះបណ្តាល ចំណុចដៅ ១០៥០ នាក់ សម្រេចបាន ៤៥០ នាក់

អនុកម្មវិធី៣.២៖ ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស និស្សិត (នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត)

- ភាគរយសិស្ស និស្សិតហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពចំណុចដៅ ៤០% សម្រេចបាន ៣៥%
- ចំនួនមេដាយប្រតិភូកីឡាសិស្សអាស៊ីអាគ្នេយ៍ និងសាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ចំណុចដៅ ១៨សម្រេចបាន ០

អនុកម្មវិធី៣.៣៖ ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា (វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា)

- ចំនួនគរុសិស្សទទួលបានការបណ្តុះបណ្តាលអប់រំកាយនិងកីឡាកម្រិតមូលដ្ឋានតាមប្រព័ន្ធ១២+២ និង១២+៤ ចំណុចដៅ ២១៦ សម្រេចបាន ១៨៣
- ចំនួនគ្រូឧទ្ទេស នៅវ.អ.ក និងគ្រូអប់រំកាយ និងកីឡានៅអនុវិទ្យាល័យ និងវិទ្យាល័យតាមរាជធានី ខេត្ត ទទួលបានការបំប៉នសមត្ថភាពចំណុចដៅ ៥៧ សម្រេចបាន ០

អនុកម្មវិធី៣.៤៖ ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ (មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា)

- ចំនួនមេដាយការប្រកួតកីឡាជាលក្ខណៈហ្គេម ចំណុចដៅ ២៣៨ មេដាយ សម្រេចបាន ៣៥៥មេដាយ

អនុកម្មវិធី៣.៥៖ ការអភិវឌ្ឍការប្រកួត និងគ្រប់គ្រង ព្រឹត្តិការណ៍កីឡាគ្រប់កម្រិត (នាយកដ្ឋានរៀបចំ និងគ្រប់គ្រងព្រឹត្តិការណ៍កីឡា)

- ចំនួនប្រភេទកីឡាបានដាក់បញ្ចូលក្នុងការប្រកួតកីឡាជាតិ (អនុវត្ត ២ឆ្នាំម្តង)
- ចំនួនប្រភេទកីឡាបានដាក់បញ្ចូលក្នុងការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិ ចំណុចដៅ ១០ សម្រេចបាន ១០
- ចំនួនប្រភេទកីឡាបានដាក់បញ្ចូលក្នុងការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិ ចំណុចដៅ ១២ សម្រេចបាន ១២
- ចំនួនវិញ្ញាសាកីឡាបានដាក់បញ្ចូលក្នុងការប្រកួតកីឡានិស្សិតឧត្តមសិក្សាថ្នាក់ជាតិ (អនុវត្ត ២ឆ្នាំម្តង)

អនុកម្មវិធី៣.៦៖ ការអភិវឌ្ឍផ្នែកព័ត៌មាន និងស្ថិតិកីឡាគ្រប់ប្រភេទ (មជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យា និងស្ថិតិកីឡា)

- ចងក្រងទិន្នន័យ និងផ្សព្វផ្សាយព្រឹត្តិការណ៍កីឡាគ្រប់ប្រភេទ ចំណុចដៅ ២៥ រាជធានី ខេត្ត ៤០ សហព័ន្ធ ១១ ក្រសួង សម្រេចបាន ០.៤
- និពន្ធ និងផលិតទស្សនាវដ្តីកីឡា ចំណុចដៅ ៦ លេខ(១២ ០០០ ក្បាល) សម្រេចបាន ០

***កម្មវិធីទី៤ "យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"*** សរុប ១ សូចនាករ មិនសម្រេចចំណុចដៅ ១ ស្មើ ១០០ភាគរយ។ កម្មវិធីទី៤ មានអនុកម្មវិធី ៣ សរុប ៥ សូចនាករ សម្រេចចំណុចដៅ ១ ស្មើ ២០ភាគរយ អាចទទួលយកបាន ២ ស្មើ ៤០ភាគរយ និងមិនបានអនុវត្ត ២ ស្មើ ៤០ភាគរយ។ លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី៤

- ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលរយៈពេលខ្លី ស្តីពីជំនាញបច្ចេកទេស ឌីជីថល សហគ្រិន និងជំនាញទន់ ចំណុចដៅ ២៧៧៧នាក់ សម្រេចបាន ១៥៤១៨នាក់

**ការសម្រេចបានសូចនាករអនុកម្មវិធី**

អនុកម្មវិធី៤.១៖ ការអភិវឌ្ឍសកម្មភាពយុវជន (នាយកដ្ឋានយុវជន)"

- ចំនួនយុវជនចូលរួមចលនាប្រឡងប្រណាំង ៣ល្អ ការងារក្រុមប្រឹក្សាយុវជនកម្ពុជា ក្រុមប្រឹក្សាកុមារកម្ពុជា និងការលើកកម្ពស់ និងអភិវឌ្ឍកម្មវិធីពាក់ព័ន្ធឌីជីថល សហគ្រិនភាព ស្វែម ភាពជាអ្នកដឹកនាំ ស្មារតីវិទ្យាសាស្ត្រ និងជំនាញទន់សម្រាប់ការអភិវឌ្ឍយុវជនចំណុចដៅ ៨០២៧នាក់ សម្រេចបាន ១៤២៣១ នាក់
- ចំនួនគ្រូបង្រៀននៅវិទ្យាល័យចំណេះដឹងទូទៅទទួលបានការបំប៉ន ចំណុចដៅ ១២នាក់ សម្រេចបាន ០០នាក់ (មិនទាន់ដល់ពេលអនុវត្ត)

អនុកម្មវិធី៤.២៖ ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន (នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល)

- ចំនួនយុវជនដែលទទួលបានជំនាញបច្ចេកទេស និងជំនាញទន់ ចំណុចដៅ ២៧៧៥នាក់ សម្រេចបាន ៧២២ នាក់
- ចំនួនមជ្ឈមណ្ឌលយុវជនដែលបានអភិវឌ្ឍន៍ ចំណុចដៅ ២ សម្រេចបាន ៣៥%

អនុកម្មវិធី៤.៣៖ ការអភិវឌ្ឍកាយវប្បកម្ម (នាយកដ្ឋានសហប្រតិបត្តិការកាយវប្ប)

- កុមារ និងយុវជន នៅបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងសហគមន៍ចូលរួមចលនាកាយវប្បសម្រេចបាន ១៧៥០ ០០នាក់ ចំណុចដៅ ១៧៥ ០០០នាក់

***កម្មវិធីទី៥ "ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ"*** សរុប១ សូចនាករ សម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន១ស្មើ១០០ភាគរយ មិនសម្រេចចំណុចដៅគ្មាន។ កម្មវិធីទី៥ មានអនុកម្មវិធី១៨ សរុប៥០ សូចនាករ សម្រេចចំណុចដៅ ៦ ស្មើ១២ភាគរយ អាចទទួលយកបាន ២៦ ស្មើ៥២ភាគរយ និងមិនបានអនុវត្ត ១៨ ស្មើ៣៦ភាគរយ។ លទ្ធផលសម្រេចបានសូចនាករកម្មវិធីទី៥

- អត្រាការទូទាត់ចំណាយថវិកាកម្មវិធីចំណុចដៅ ៩៥% សម្រេចបាន ៤៨%

**ការសម្រេចបានសូចនាករអនុកម្មវិធី**

អនុកម្មវិធី៥.១៖ ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធផែនការអប់រំ (នាយកដ្ឋានផែនការ)"

- របាយការណ៍ពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ត្រូវបានរៀបចំ ចំណុចដៅ ១០០% សម្រេចបាន ១០%
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ ត្រូវបានរៀបចំ ចំណុចដៅ ១០០% (សេចក្ដីព្រាងដំបូង)
- របាយការណ៍ពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃផែនការគោលអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ២០២០-២០២៤ ត្រូវបានរៀបចំ ចំណុចដៅ ១០០% សម្រេចបាន ០%
- ចំនួនរាជធានី ខេត្ត មានផែនការប្រតិបត្តិប្រចាំឆ្នាំមានគុណភាពចំណុចដៅ ១៧ សម្រេចបាន ១៤
- ភាគរយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានផែនការប្រតិបត្តិប្រចាំឆ្នាំ ចំណុចដៅ ៧៥% សម្រេចបាន ៦៥.២%

អនុកម្មវិធី៥.២៖ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស (នាយកដ្ឋានបុគ្គលិក)

- ចំនួនអង្គភាពបានបំពេញសលាកបត្រជូនគរុសិស្ស និស្សិតដែលត្រៀមចេញបម្រើការងារ ដើម្បីរៀបចំប្រាក់បៀវត្សចំណុចដៅ ២៥ អង្គភាព សម្រេចបាន ០
- ចំនួនអង្គភាពដែលត្រូវបានចុះសហការពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តគោលការណ៍ស្ដីពីការគ្រប់គ្រង និងការបំពេញភារកិច្ចរបស់ បុគ្គលិកអប់រំ គ្រូបង្រៀន និងមន្ត្រីជាប់កិច្ចសន្យា ចំណុចដៅ ២៥ អង្គភាព សម្រេចបាន ១៩ អង្គភាព
- ចំនួនរាជធានី ខេត្ត និង គ្រឹះស្ថានសិក្សាត្រូវបានចុះពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តគោលការណ៍ស្ដីពីការប្រឡងជ្រើសរើសចូលក្របខណ្ឌគ្រូបង្រៀន ចំណុចដៅ ២៥ អង្គភាព សម្រេចបាន ២១ អង្គភាព
- ចំនួនគរុសិស្ស និស្សិត ដែលប្រឡងបញ្ចប់ការបណ្ដុះបណ្ដាលទទួលបានការតម្រង់ទិសមុនពេល ចេញបម្រើការងារចំណុចដៅ ៣ ០០០ នាក់ សម្រេចបាន ៨ នាក់

អនុកម្មវិធី៥.៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាព ការគាំទ្រការលើកកម្ពស់គុណ ភាពអប់រំ និងមូលដ្ឋានសម្ភារៈ (នាយកដ្ឋានហិរញ្ញវត្ថុ)

- អត្រាការទូទាត់ចំណាយថវិកាកម្មវិធីចំណុចដៅ ៩៥% សម្រេចបាន ៤៨%
- អត្រាកំណើនថវិកាចំណាយចរន្តធៀបនឹងចំណាយចរន្តថ្នាក់ជាតិ ចំណុចដៅ ២០% សម្រេចបាន ១៦%

អនុកម្មវិធី៥.៤៖ ការពង្រឹងការងារសវនកម្មផ្ទៃក្នុង (នាយកដ្ឋានសវនកម្មផ្ទៃក្នុង)

- ចំនួនអង្គភាពបានត្រួតពិនិត្យតាមដានការកែលម្អតាមអនុសាសន៍ ចំណុចដៅ ២០ សម្រេចបាន ៣
- ចំនួនអង្គភាពរងសវនកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ" ចំណុចដៅ១២៤ សម្រេចបាន ៦៤
- ចំនួនអង្គភាពរងសវនកម្មសមិទ្ធកម្ម និងអង្គភាពរងសវនកម្មបច្ចេកវិទ្យាព័ត៌មាន (សាកល្បង) ១២ ៧
- ចំនួនអង្គភាពរងសវនកម្មលើគម្រោងដែលប្រើហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ចំណុចដៅ ៤ សម្រេចបាន ១
- ចំនួនមន្ត្រីសវនកម្មផ្ទៃក្នុងទទួលបានការពង្រឹងសមត្ថភាព ចំណុចដៅ ២២០ សម្រេចបាន ១៣៥

អនុកម្មវិធី៥.៥៖ ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ចប្រព័ន្ធធានាគុណភាពអប់រំ (នាយកដ្ឋានធានាគុណភាពអប់រំ)

- តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ថ្នាក់ជាតិ ថ្នាក់ទី៣,៦,៨ និងទី១១ " ថ្នាក់ទី១១ (២៣០សាលា) សម្រេចបាន ៤៣%
- តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស បឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ ថ្នាក់ទី៥ "អនុវត្តសាកល្បង SEA-PLM ២០២៤ (៣៥សាលា)" ២៥%
- កម្មវិធីអន្តរជាតិស្តីពីតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស វិភាគ និងសរសេររបាយការណ៍ PISA-២០២២ សម្រេចបាន ៥២%
- ចំនួនគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សានឹងត្រូវបានធ្វើអធិការកិច្ចតាមប្រធានបទចំនួន២ ចណុចដៅបឋមសិក្សា ១០០ មធ្យមសិក្សា ១០០ សម្រេចបាន ៥០%
- ចំនួនរាជធានី ខេត្ត ត្រូវបានចុះពិនិត្យតាមដានគុណភាព និងប្រសិទ្ធភាពអប់រំ ចំណុចដៅ ២៥រាជធានី ខេត្ត" សម្រេចបាន ១០រាជធានី ខេត្ត"

អនុកម្មវិធី៥.៦៖ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ (អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ)"

- ចំនួនអង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានចុះធ្វើអធិការកិច្ចជាប្រចាំ ចំណុចដៅ៣៤៩ ម្រេចបាន ៩០
- ចំនួនអង្គភាពត្រូវបានពិនិត្យវឌ្ឍនភាពនៃការកែលម្អតាមអនុសាសន៍ ចំណុចដៅ២០ ម្រេចបាន០
- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ និងផ្សព្វផ្សាយរបាយការណ៍អធិការកិច្ច ចំណុចដៅ ២ វគ្គ សម្រេចបាន ១ វគ្គ
- អធិការកិច្ចចៃដន្យ ចំណុដៅ ១២ ករណី សម្រេចបាន ៦ ករណី

អនុកម្មវិធី៥.៧៖ លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអប់រំ និងសហប្រតិបត្តិការអាស៊ាន-ស៊ីមេអូ (នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន)

- ព័ត៌មានស្តីពីការអប់រំត្រូវបានប្រមូល ចងក្រង និងផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន (ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្តី ផ្ទាំងរូបភាព និងប័ណ្ណផ្អត់)ចំណុចដៅ ៩ ០០០ ផ្ទាំង ២៥ ០០០ សន្លឹក សៀវភៅ ១ ២០០ក្បាល សម្រេចបាន ១ ០០០ ផ្ទាំង សៀវភៅ ៤០០ក្បាល
- ចំនួនសិស្សនិស្សិត ដែលចូលរួម និងទទួលបានលទ្ធផលក្នុងការធ្វើតេស្តវាយតម្លៃ ចំណេះដឹងអាស៊ាន-ស៊ីមេអូ តាមឌីជីថល និងដោយផ្ទាល់ ចំណុចដៅ ៤០០ នាក់ សម្រេចបាន ៣០០នាក់

- ភាពយន្ត-វីដេអូអប់រំ-ស្ប៉តអប់រំ និងឯកសារសមិទ្ធផលអប់រំ យុវជន និងកីឡាត្រូវបានផលិត និងផ្សព្វផ្សាយ ចំណុចដៅ ៨៥% សម្រេចបាន ៨៥%
- ចំនួនមន្ត្រីអប់រំត្រូវបានអភិវឌ្ឍសមត្ថភាព លើជំនាញព័ត៌មាន និងលើកកម្ពស់ចំណេះដឹង និងផ្សព្វផ្សាយ ចក្ខុវិស័យលទ្ធផលកិច្ចប្រជុំអាស៊ាន-ស៊ីមេអូ ចំណុចដៅ ២០០ នាក់ សម្រេចបាន ១០០ នាក់
- ចំនួនកិច្ចប្រជុំអាស៊ាន-ស៊ីមេអូ ត្រូវផលិត និងផ្សព្វផ្សាយ ចំណុចដៅ ១៥០ លើក សម្រេចបាន ៥០លើក

អនុកម្មវិធី៥.៨៖ ការពង្រឹងការងារនីតិកម្ម (នាយកដ្ឋាននីតិកម្ម)

- ចំនួនលិខិតបទដ្ឋានគតិយុត្តិវិស័យអប់រំត្រូវបានរៀបចំ ចំណុចដៅ ៣០ សម្រេចបាន ៨
- ចំនួនបុគ្គលិកអប់រំ និងគរុនិស្សិតទទួលបានការអភិវឌ្ឍសមត្ថភាពលើការងារនីតិកម្មវិស័យអប់រំ ចំណុចដៅ ៣១៦០នាក់ សម្រេចបាន ១១៦៣នាក់
- ចំនួនបុគ្គលិកអប់រំដែលត្រូវបានធ្វើការសិក្សាលើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌច្បាប់វិស័យអប់រំចំណុចដៅ ២០០ សម្រេចបាន ២៤

អនុកម្មវិធី៥.៩៖ ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ (នាយកដ្ឋានសំណង់)

- ចំនួនទីតាំងគម្រោងសាងសង់ថ្មី ជួសជុល និងចុះពិនិត្យតាមដានលក្ខណៈបច្ចេកទេសព្រមទាំងការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ ៦០០ ៤០០
- ចំនួនអគារសិក្សាសាលារៀនដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិខ្នាតតូច ត្រូវបានជួសជុលបំពេញតម្រូវការ ជំណុចដៅ ១៨២ សម្រេចបាន ០
- ចំនួនមន្ត្រីជំនាញថ្នាក់ក្រោមជាតិ និងនាយក នាយិកាសាលា ទទួលបានការបណ្តុះបណ្តាលអំពីការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ ចំណុចដៅ ២៣៥ សម្រេចបាន ០

អនុកម្មវិធី៥.១០៖ ការពង្រឹងការគ្រប់គ្រងការផ្គត់ផ្គង់សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ (នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ)

- ចំនួនអង្គភាពរដ្ឋបាលកណ្តាល និងមន្ទីរ មានបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ចំណុចដៅ ៦១ សម្រេចបាន ៣៦
- ចំនួនគ្រឹះស្ថានសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមានសម្ភារបរិក្ខារសម្រាប់រដ្ឋបាល ចំណុចដៅ ៧៥ សម្រេចបាន ០%

អនុកម្មវិធី៥.១១៖ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាភាពស័ក្តសិទ្ធនៃសេវារដ្ឋបាលអប់រំ (នាយកដ្ឋានរដ្ឋបាល )

- ចំនួនបុគ្គលិកអប់រំ ថ្នាក់ជាតិ ក្រោមជាតិ អង្គការជាតិ និងអន្តរជាតិ បានចូលរួមពិធី សន្និបាតអប់រំប្រចាំឆ្នាំ ចំណុចដៅ ៥០០ សម្រេចបាន ១០០%
- ចំនួនបុគ្គលិកអប់រំ បានចូលរួមវគ្គបំប៉នស្តីពីការគ្រប់គ្រងរដ្ឋបាល បណ្ណសារ ពិធីការអប់រំ និងប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាលចំណុចដៅ ១៦៨ សម្រេចបាន ០

អនុកម្មវិធី៥.១២៖ ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិលើវិស័យអប់រំ (នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍)

- ចំនួនកម្មវិធីប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេស និងសកម្មភាពកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិលើវិស័យអប់រំ និងសេវាអន្តេវាសិកដ្ឋាននិស្សិតនារី ត្រូវបានអនុវត្តចំណុចដៅ ១៥ សម្រេចបាន ៨

អនុកម្មវិធី៥.១៣៖ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ)

- សៀវភៅស្ថិតិ និងសូចនាករអប់រំត្រូវបានផលិត និងផ្សព្វផ្សាយតាមឆ្នាំសិក្សាចំណុចដៅ ១០០% សម្រេចបាន ១០០%
- បង្កើនការប្រមូល និងផលិតស្ថិតិសូចនាករអប់រំ ចំណុចដៅ ១០០% សម្រេចបាន ១០០%

អនុកម្មវិធី៥.១៤៖ ការស្រាវជ្រាវ និងអភិវឌ្ឍគោលនយោបាយអប់រំ (នាយកដ្ឋានគោលនយោបាយ)

- ចំនួនគោលនយោបាយអប់រំ យុវជន និងកីឡា ត្រូវបានពិនិត្យតាមដាន វាយតម្លៃ និងសម្របសម្រួលការអនុវត្ត ១គោលនយោបាយ សម្រេចបាន ៥០%"
- ចំនួនគោលនយោបាយអប់រំ យុវជន និងកីឡា ត្រូវបានរៀបចំ កែសម្រួល និងផ្សព្វផ្សាយ ១គោលនយោបាយ សម្រេចបាន ៣០%

អនុកម្មវិធី៥.១៥៖ ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ (នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ)

- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំត្រូវបានរៀបចំ ចំណុចដៅ ១០០%(៤ដងក្នុង១ឆ្នាំ) សម្រេចបាន ៥០%
- របាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាប្រចាំឆ្នាំ ចំណុចដៅ ១០០% (អនុវត្តនៅត្រីមាសទី៤)

អនុកម្មវិធី៥.១៦៖ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងារអប់រំ យុវជន និងកីឡា (នាយកដ្ឋានព័ត៌មាន)

- ចំនួនមាតិកាអប់រំឌីជីថល ត្រូវបានផលិតគាំទ្រដល់ការបង្រៀន និងរៀនពីចម្ងាយនិង តាមប្រព័ន្ធ អេឡិចត្រូនិក និងការផ្សព្វផ្សាយព័ត៌មានអប់រំឌីជីថលនៅលើគេហទំព័រធនធានអប់រំ និងបណ្តាញសង្គម ផ្លូវការក្រសួងអប់រំ យុវជន និងកីឡា ឲ្យកាន់តែសម្បូរបែប ចំនុចដៅ ២៥០ មាតិកា សម្រេចបាន ១៤៩ មាតិកា
- ចំនួនសាលារៀនដែលបានតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការផ្គត់ផ្គង់សម្ភារបច្ចេកទេសព័ត៌មានវិទ្យា និងការកសាងប្រព័ន្ធគ្រប់គ្រងមាតិកាអប់រំ សម្រាប់គាំទ្រការបង្រៀននៅកម្រិតបឋម និងមធ្យមសិក្សា ក្នុងបរិបទថ្មីឱ្យកាន់តែទូលំទូលាយចំនុចដៅ ៥០ សម្រេចបាន ២៥
- ចំនួនបុគ្គលិកអប់រំ និងគ្រូបង្រៀន ទទួលបានការអភិវឌ្ឍសមត្ថភាពបំណិនបច្ចេកវិទ្យាព័ត៌មាន សម្រាប់ ការងារគ្រប់គ្រងអប់រំ ការបង្រៀនរៀន ទាំងក្នុង-ក្រៅប្រទេស តាមរយៈការសិក្សាតាមប្រព័ន្ធអេឡិចត្រូចនិក និងតាមបែបចម្រុះ" ចំនុចដៅ ១០០០ សម្រេចបាន ៣០០

អនុកម្មវិធី៥.១៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សានិងអប់រំបច្ចេកទេស (នាយកដ្ឋានកិច្ចការប្រឡង)

- ចំនួនបុគ្គលិកអប់រំ ទទួលបានការបំប៉នសមត្ថភាពស្តីពីការធ្វើអក្សរសម្ងាត់ និងចូលរួមសិក្ខាសាលា ស្តីពីតួនាទី និងភារកិច្ចជំនួយការនិងអប្បមាទទូទាំងប្រទេសសម្រាប់ដំណើរការប្រឡងសញ្ញាបត្រមធ្យម សិក្សាទុតិយភូមិ ចំណុចដៅ ៣ ៥៤០ នាក់ (អនុវត្តនៅត្រីមាសទី៣)

**រូបភាពទី ៥ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករតាមអនុកម្មវិធីនៃកម្មវិធីទាំង៥**



## ៣. ចន្លោះនភាពនៃការអនុវត្តតាមកម្មវិធី
### ៣.១ កម្មវិធីទី១៖ ការពង្រីកកម្មវិធីទំនើបនៃមតេយ្យ និងអប់រំក្រៅប្រព័ន្ធ
#### ៣.១.១. ការពង្រីកការអប់រំកុមារតូច
***ការសម្រេចបានសូចនាករ***
- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***
- ការផ្តល់សម្ភារៈបង្រៀននិងរៀន សម្រាប់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ស្តង់ដា ១៣៥០ កន្លែង
- ការវាយតម្លៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ។

***បញ្ហាប្រឈម*** (គ្មាន)
#### ៣.១.២. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា
***សូចនាករ***
- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ៣៣,៣៣ភាគរយ អាចទទួលយកបាន ១ ស្មើ ៣៣,៣៣ភាគរយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ៣៣,៣៣ ភាគរយ។

***ផលសម្រេច ៖***
- ការកែលម្អសៀវភៅពន្លឿនការសិក្សាថ្នាក់ឆ្នាំទី១
- ការពិគ្រោះយោបល់ស្តីពីការកសាងសៀវភៅរឿងជាភាសាគ្រឹង និងភាសាព្នង
- ការកសាងសៀវភៅកញ្ចប់អំណានថ្នាក់ទី៣ លើកទី៩
- ការបញ្ចប់ឯកសារសេចក្តីព្រាងស្តីពី «ការរៀបចំ និងរបៀបប្រើប្រាស់សម្ភារៈរៀន និងបង្រៀនគណិតវិទ្យាថ្នាក់ទី៣
- វគ្គសិក្ខាសាលា ស្តីពីអភិក្រម ប្រព័ន្ធដើម្បីទទួលបានលទ្ធផលអប់រំ កាន់តែប្រសើរ (SABER)
- ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់ កសិផលក្នុងសហគមន៍
- ការកែលម្អកម្រងសំណួរដោយលក្ខណៈស្តង់ដាប្រចាំខែលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី១ដល់ទី៦។

***បញ្ហាប្រឈម***
- ខ្វះមន្ត្រីជាពិសេសអ្នកជំនាញភាសាបរទេស និងបច្ចេកវិទ្យព័ត៌មាន ។

#### ៣.១.៣. ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា
***សូចនាករ***
- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ ២ ស្មើ ៤០ភាគរយ អាចទទួលយកបាន២ ស្មើ ៤០ភាគរយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ២០ភាគរយ។

***ផលសម្រេច***
- ពង្រឹង ពង្រីកសាលារៀនជំនាន់ថ្មី
- ចុះជួយផ្នែកបច្ចេកទេសដល់ថ្នាក់មូលដ្ឋាន។

***បញ្ហាប្រឈម***
- អង្គភាពទើបទទួលបានថវិកាសម្រាប់ដំណើរការកម្មវិធីនៅចុងត្រីមាស សម្រាប់ធមាសទី១។

#### ៣.១.៤. ការពង្រីកការអប់រំក្រៅប្រព័ន្ធ
***សូចនាករ***
- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ ២ ស្មើ ៤០ភាគរយ អាចទទួលយកបាន

គ្មាន និងមិនសម្រេចចំណុចដៅ ៣ ស្មើ ៦០ភាគរយ។

***ផលសម្រេច***

- ការពង្រឹងនិងពង្រីកកម្មវិធីអក្ខរកម្មសម្រាប់កម្មករ កម្មការិនីរោងចក្រ កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអនឡាញ(ប៊ីប) និងកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ
- ការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីបំណិនជីវិតនិងមុខរបរងាយៗ កម្មវិធីសមមូលបឋមសិក្សា សមមូលមធ្យម
- សិក្សាបឋមភូមិ និងកម្មវិធីចូលរៀនឡើងវិញតាមបែបចម្រុះ តាមបណ្ដុំ និងតាមប្រព័ន្ធអេឡិចត្រូនិក
- ការលើកកម្ពស់ការអនុវត្តកម្មវិធីអក្ខរកម្មនិងការអនុវត្តកម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិអប់រំក្រៅប្រព័ន្ធ
- ការធ្វើបច្ចុប្បន្នកម្មកម្មវិធី និងសៀវភៅសិក្សាអក្ខរកម្ម
- ការផលិតវីដេអូ បង្រៀន និងរៀនសម្រាប់កម្មវិធីអក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សា
- ការរៀបចំសេចក្ដីព្រាងឯកសារបណ្ដុះបណ្ដាលគ្រូបង្រៀនជាប់កិច្ចសន្យាកម្មវិធីអក្ខរកម្មនិងកម្មវិធីសមមូលបឋមសិក្សា
- អប់រំក្រៅប្រព័ន្ធតាមប្រព័ន្ធក្រេឌីត
- ការផ្ដល់សម្ភារៈ និងបំពាក់ប្រព័ន្ធអ៊ីនធឺណិតតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត
- ការវាយតម្លៃមជ្ឈមណ្ឌលសិក្សាសហគមន៍
- ការអនុវត្តក្របខណ្ឌវាយតម្លៃស្ថានភាពដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍។

***បញ្ហាប្រឈម***(គ្មាន)

**៣.១.៥. ការពង្រឹង និងការពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា**

***សូចនាករ***

- សូចនាករសរុប ៧ (វាយតម្លៃលទ្ធផលសម្រេចនៅចុងឆ្នាំ)។

***ផលសម្រេច***

- ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅសិក្សាគោល"សុខភាពសិក្សាសម្រាប់អ្នកទាំងអស់គ្នា"
- ការអភិវឌ្ឍសមត្ថភាព និងពង្រឹងគុណភាពគ្រូបង្រៀនមុខវិជ្ជា "អប់រំសុខភាព"
- កម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំសុខភាពសម្រាប់បណ្ដុះបណ្ដាលគ្រូបឋមសិក្សា១២+២ តាមប្រព័ន្ធក្រេឌីត
- ការអនុវត្តការរៀននិងបង្រៀនមុខវិជ្ជា "អប់រំសុខភាព" នៅថ្នាក់ទី៥ ទី៦ ទី៧ ទី៨ ទី១០ និងថ្នាក់ទី១១
- ការប្រគល់-ទទួលសៀវភៅសិក្សាគោលមុខវិជ្ជា "អប់រំសុខភាព" សម្រាប់គ្រូ-សិស្ស ថ្នាក់ទី១ ទី៤ ទី៧ និងថ្នាក់ទី១០។

***បញ្ហាប្រឈម***

- កង្វះមន្ត្រីជំនាញផ្នែកវិទ្យាសាស្ត្រសុខាភិបាលនិងសុខភាពសាធារណៈ និងសម្ភារៈអេឡិចត្រូនិក
- កង្វះថវិកាផ្សព្វផ្សាយ ស្ដីពីការលើកកម្ពស់សុខភាពសិក្សា បន្ទប់សុខភាពនិងការពិនិត្យតាមដាន។

**៣.១.៦. លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ១០០ភាគរយ អាចទទួលយកបានគ្មាន និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***

- ការរៀបចំសេចក្ដីព្រាងកម្មវិធីសិក្សាជំនាញឌីជីថល មេឌាឌីហ្សាញ

- ការរៀបចំសេចក្តីព្រាងកម្មវិធីសិក្សាជំនាញកុំព្យូទ័រ
- ការរៀបចំកែសម្រួលលើសៀវភៅក្លឹបសិក្សាចំនួន ០៨ម៉ូឌុល
- ការរៀបចំណែនាំស្តីពី« ការប្រើប្រាស់បន្ទប់បំណិនជីវិតពហុបំណងនៅតាមវិទ្យាល័យគោលដៅ
- ការវាយតម្លៃលើការអនុវត្តមុខវិជ្ជារោងជាងអប់រំបំណិនជីវិតចំនួន ៤ខេត្ត។

*បញ្ហាប្រឈម*

- ការទម្លាក់ថវិកាយឺតសម្រាប់ដំណើរការកម្មវិធីនៅចុងត្រីមាស សម្រាប់ឆមាសទី១។

**៣.១.៧. ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងក្រឹតការគ្រូបង្រៀន**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ (វាយតម្លៃលទ្ធផលសម្រេចនៅចុងឆ្នាំ)។

*ផលសម្រេច*

- ការអភិវឌ្ឍក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងស្តង់ដាវិជ្ជសជីវៈគ្រូឧទ្ទេស
- ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស ផ្តោតលើប្រធានបទ TED៣: ចំណេះដឹងខ្លឹមសារបច្ចេកវិទ្យាគរុកោសល្យ, TED៤: ភាពជាអ្នកដឹកនាំ,TED៥
- វគ្គបំប៉នស្តីពី ការអប់រំបរិយាបន្ន និងការគ្រប់គ្រងតាមសាលារៀន
- វគ្គបណ្តុះបណ្តាលស្តីពី ការរៀបចំសរសេរគម្រោងអភិវឌ្ឍសាលារៀន គ្រូមត្តេយ្យស្ម័គ្រចិត្តជំណាក់កាលទី១ សុខភាពមករដូវ និងភាពពេញវ័យ។

*បញ្ហាប្រឈម*

- កង្វះមន្ត្រីជំនាញព័ត៌មានវិទ្យា និងកម្មវិធីសិក្សា។

**៣.១.៨. ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ ២ ស្មើ ១០០ភាគរយ អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- សេចក្តីព្រាងលើកទី១ សៀវភៅសិក្សាគោលមុខវិជ្ជា សីលធម៌ -ពលរដ្ឋ ភូមិវិទ្យា ប្រវត្តិវិទ្យា និងសេដ្ឋកិច្ច
- ការពង្រឹងសកម្មភាពមេត្រីបរិស្ថាន និងក្លឹបមេត្រីបរិស្ថានឡើងវិញ ១០ សាលារៀន
- ការពិនិត្យតាមដានការផ្គត់ផ្គង់ និងការគ្រប់គ្រងសៀវភៅសិក្សាគោល ១១៩សាលារៀន។

*បញ្ហាប្រឈម*

- នាយកសាលានិងបណ្ណារក្សមិនទាន់អាចធ្វើតម្រូវការសៀវភៅសិក្សាបានត្រឹមត្រូវ
- សាលារៀនមួយចំនួនមិនមានបណ្ណារក្ស ។

**៣.១.៩. ពង្រីកការអប់រំបរិយាបន្នគ្រប់កម្រិតសិក្សា**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំសរុប ៣ ក្នុងនោះសម្រេចចំណុចដៅ ២ ស្មើ ៦៦,៦៧ភាគរយ អាចទទួលយកបាន ១ស្មើ ៣៣,៣៣ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- វគ្គបំប៉នសមត្ថភាពគ្រូបង្រៀនថ្នាក់សមាហរណកម្មស្តីពី "ការអប់រំកុមារមានពិការភាពសតិបញ្ញា និងអូទីស្សឹម"
- វគ្គបំប៉នសមត្ថភាពដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន ស្តីពី "ការអប់រំបរិយាបន្ន" ខេត្តសៀមរាប ៥៥នាក់

- វគ្គបំប៉នសមត្ថភាពដល់គ្រូបង្រៀនស្តីពី "ភាសាសញ្ញាថ្មី"។

*បញ្ហាប្រឈម*

- គ្រូបង្រៀននៅវិទ្យាល័យអប់រំពិសេសនិងថ្នាក់សមាហរណកម្មមិនទាន់បានបំប៉នសមត្ថភាពវិធីសាស្ត្របង្រៀននិងបច្ចេកទេសថ្មីៗឆ្លើយតបនឹងតម្រូវការ
- កង្វះថវិកាគាំទ្រការអនុវត្តកម្មវិធីអប់រំបរិយាបន្នគ្រប់ភូមិសិក្សា និងគ្រូបង្រៀនថ្នាក់អប់រំពហុភាសា
- ការផលិតសៀវភៅសិក្សាភាសាចារាយ មិនទាន់សម្រេចបានតាមការគ្រោងទុក។ គ្រូបង្រៀនថ្នាក់អប់រំពហុភាសា

**៣.១.១០. ការគាំទ្រការអប់រំបរិយាបន្ន**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំសរុប ១ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ១ស្មើ ១០០,០០ ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- ការបោះពុម្ពឯកសារជាអក្សរប្រែយ៍បានចំនួន៧២៦ក្បាល ស្មើនឹង៧៥៤៤៨ទំព័រ
- ការបណ្តុះបណ្តាលគ្រូនៅតាមវិទ្យាល័យអប់រំពិសេសស្តីពីការប្រើប្រាស់ម៉ាស៊ីន និងឯកសារអក្សរប្រែយ៍
- ការស្រាវជ្រាវសញ្ញាថ្មីពីវិទ្យាល័យអប់រំពិសេសបានចំនួន២៤០សញ្ញា។

*បញ្ហាប្រឈម*

- កង្វះមន្ត្រីជំនាញ និងសម្ភារៈផលិតឯកសារអក្សរប្រែយ៍ និងភាសាសញ្ញា។

**រូបភាពទី ៦ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករតាមអនុកម្មវិធីក្នុងកម្មវិធីទី១**




## ៣.២ កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ

**៣.២.១. ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ១០០ភាគរយ អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- ការបណ្តុះបណ្តាលស្តីពីការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ៤៩ គ្រឹះស្ថានឧត្តមសិក្សា។

*បញ្ហាប្រឈម*

- ការរៀបចំផែនការមិនបានលម្អិតសម្រាប់អនុវត្តផែនការប្រតិបត្តប្រចាំឆ្នាំ។

**៣.២.២. ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ ៤ ស្មើ ៨០ភាគរយ អាចទទួលយកបាន ១ ស្មើ ២០ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- ការប្រកាសឋានៈសាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយក្នុងវិស័យអប់រំ
- ការរៀបចំរបាយការណ៍ស្រាវជ្រាវស្តីពីការអប់រំថ្នាក់ក្រោយបរិញ្ញាបត្រនៅកម្ពុជា
- ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងបោះពុម្ពទស្សនាវដ្តីស្រាវជ្រាវ។

*បញ្ហាប្រឈម*

- ការទូទាត់ថវិកាស្មុគស្មាញ
- កង្វះមន្ត្រីជំនាញផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យា ព្រមទាំងសម្ភារៈអេឡិចត្រូនិក។

**៣.២.៣. ការពង្រឹងគុណភាព និងភាពឆ្លើយតបនៃការបណ្តុះបណ្តាលកម្រិតឧត្តម និងក្រោយឧត្តមប្រកបដោយប្រសិទ្ធភាព (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ (វាយតម្លៃលទ្ធផលសម្រេចនៅចុងឆ្នាំ)។

*ផលសម្រេច*

- ការផលិតធនធានមនុស្សមានសមត្ថភាព និងជំនាញតាមកម្មវិធីថ្មី ស្របតាមទីផ្សារការងារបច្ចុប្បន្ន
- ការអនុវត្តក្នុងកម្មវិធី Cyber Universityលើមុខវិជ្ជា០២ ក្នុងប្រព័ន្ធធានាគុណភាពផ្ទៃក្នុង។

*បញ្ហាប្រឈម*

- ការផ្តល់ទិន្នន័យសម្រាប់រៀបចំរបាយការណ៍យឺត។

**៣.២.៤. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ (សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ (វាយតម្លៃលទ្ធផលសម្រេចនៅចុងឆ្នាំ)។

*ផលសម្រេច*

- ការរៀបចំវគ្គសិក្ខាសាលាស្តីពី SWAMP, Ind. ៤.០, DX...SEA, ។

*បញ្ហាប្រឈម*

- កង្វះថវិកាសម្រាប់ការស្រាវជ្រាវ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ

**៣.២.៥.លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលនិងការស្រាវជ្រាវ (សាកលវិទ្យាល័យជាតិ ជា ស៊ីម កំចាយមារ)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ។

*ផលសម្រេច*

- ការបណ្តុះបណ្តាលស្តីពីការរៀបចំរបាយការណ៍វាយតម្លៃកម្មវិធីគណនេយ្យ ក្សេត្រសាស្ត្រ និងអភិវឌ្ឍន៍ជនបទ។

*បញ្ហាប្រឈម*

- កង្វះថវិកាសម្រាប់ការស្រាវជ្រាវ។

**៣.២.៦. ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះសម្រេចចំណុចដៅ ២ ស្មើ ៦៦,៦៧ភាគរយ អាចទទួលយកបាន ១ ស្មើ ៣៣,៣៣ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រត្រូវផ្សព្វផ្សាយ១២៥ប្រធានបទ និងបោះពុម្ពផ្សាយ ៧៩ប្រធានបទ
- ការបណ្តុះបណ្តាលអំពីការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២៥ដង។

*បញ្ហាប្រឈម*

- កង្វះមន្ត្រីយល់ដឹងពីរចនាសម្ព័ន្ធគោលនយោបាយ កម្មវិធី/អនុកម្មវិធី និងចង្កោមសកម្មភាព។

**៣.២.៧.ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការណ្តុះបណ្តាល និងស្រាវជ្រាវ (វិទ្យាស្ថានជាតិអប់រំ)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ៥ ស្មើ ១០០ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- ការប្រកាសផ្តល់ឋានៈស្មើអគ្គនាយកដ្ឋាន និងការបង្កើតដេប៉ាតឺម៉ង់ស្រាវជ្រាវ
- ការអនុវត្តកម្មវិធីបណ្តុះបណ្តាលបំណិនគរុកោសល្យសតវត្សទី២១។

*បញ្ហាប្រឈម*

- នីតិវិធីច្រើនក្នុងការអនុវត្តថវិកា។

**៣.២.៨. ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ (សាកលវិទ្យាល័យស្វាយរៀង)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ។

*ផលសម្រេច*

- ការផលិតសៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវជ្រាវអំពីកសិកម្ម សង្គមសាស្ត្រ វិស្វកម្ម និងបច្ចេកវិទ្យា
- ការអនុវត្តគម្រោងស្រាវជ្រាវ០៦ និងបោះពុម្ពអត្ថបទស្រាវជ្រាវជាអន្តរជាតិ០៣។

*បញ្ហាប្រឈម*

- ពុំទាន់បានដំណើរការល្អក្នុងការអនុវត្តន៍ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងការងារ
- បញ្ហានិស្សិតរៀនផ្នែក STEM មានចំនួនតិចមិនសម្រេចតាមគោលដៅ។

**៣.២.៩. ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ (សាកលវិទ្យាល័យជាតិមានជ័យ)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចចំណុចដៅ ៣ ស្មើ ៧៥ភាគរយ អាចទទួលយកបាន ១ ស្មើ ២៥ ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- រៀបចំសេចក្តីព្រាងគោលកាណ៍ចុះកម្មសិក្សា
- រៀបចំនិងកែលម្អគម្រោងមុខវិជ្ជាមួយចំនួននៃកម្មវិធីអប់រំ
- រៀបចំគម្រោងកែច្នៃផលិតផលកសិកម្មជាលក្ខណៈគ្រួសារនៅក្នុងខេត្តបន្ទាយមានជ័យ
- រៀបចំព្រាងអនុស្សារណៈយោគយល់ជាមួយសាលាអន្តរជាតិ យូ អេស អេ សាខាក្រុងសិរីសោភ័ណនិងគម្រោងSAAMBATបណ្តុះបណ្តាលបច្ចេកទេសនៃការចិញ្ចឹមឃ្មុំ ដល់យុវជនចំនួន៩០នាក់។

*បញ្ហាប្រឈម*

- កង្វះបន្ទប់សិក្សា
- ទីតាំងលេចទឹករាល់ឆ្នាំខូចហេដ្ឋារចនាសម្ព័ន្ធ។

**៣.២.១០. ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ (សាកលវិទ្យាល័យជាតិបាត់ដំបង)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ៣ ស្មើ ១០០ ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- រៀបចំកម្មវិធីនិស្សិតស្រាវជ្រាវគំរូដើម ម៉ូឌែលអាជីវកម្ម និងគម្រោងស្រាវជ្រាវអនុវត្ត
- រៀបចំការការពារគម្រោងស្រាវជ្រាវថ្នាក់បរិញ្ញាបត្រ
- ការចុះអនុស្សរណៈរវាងសាកលវិទ្យាល័យជាមួយ ទីភ្នាក់ងារឧត្តមសិក្សា និងសាកលវិទ្យាល័យផ្សេងៗ។

*បញ្ហាប្រឈម*

- កង្វះបន្ទប់សិក្សានិងគ្រូបង្រៀនលើជំនាញស្ថាបត្យកម្ម សំណង់ អគ្គិសនី អេឡិចត្រូនិច ស្វ័យប្រវត្តិកម្ម បច្ចេកវិទ្យាព័ត៌មាន និងមន្ត្រីរដ្ឋបាល
- សកម្មភាពក្នុងផែនការមិនអាចអនុវត្តតាមផែនការ។

**៣.២.១១. ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា (គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ ១ ស្មើ ១០០ភាគរយ។

*ផលសម្រេច*

- ការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា។

*បញ្ហាប្រឈម*

- កង្វះថវិកាគាំពារការបណ្តុះបណ្តាលគ្រឹះស្ថានឧត្តមសិក្សា និងការរៀបចំស្តង់ដា។

**៣.២.១២. ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវលើផ្នែកបច្ចេកទេសវិជ្ជាជីវៈ និងសេវាសហគមន៍ (វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ២ ស្មើ ១០០ ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- ការបណ្តុះបណ្តាល ការផ្តល់សេវាកម្មបច្ចេកទេសដល់សហគមន៍ និងការស្រាវជ្រាវពី STEM
- ការគាំទ្រគម្រោងស្រាវជ្រាវទាក់ទងនឹងការផ្សារភ្ជាប់រវាងមុខរបរប្រចាំថ្ងៃរបស់សហគមន៍ និងបច្ចេកវិទ្យា។

*បញ្ហាប្រឈម*

- ការទម្លាក់ថវិកាយឺតសម្រាប់សាងសង់អគារសិក្សា និងអគារពិសោធន៍
- សមត្ថភាពមន្ត្រីនៅមានកម្រិតក្នុងការប្រើប្រាស់ឧបករណ៍ទំនើបថ្មីៗ។

**៣.២.១៣. ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ (សាកលវិទ្យាល័យក្រចេះ)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ៣ ស្មើ ៧៥ភាគ

រយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ២៥ភាគរយ។

***ផលសម្រេច***

- ការអនុវត្តគម្រោងស្រាវជ្រាវចំនួន ០៥
- ការចុះអនុស្សរណៈជាមួយសាកលវិទ្យាល័យ និងការផ្លាស់ប្តូរសាស្ត្រាចារ្យក្នុងការបង្រៀន និងការបង្កើតគម្រោង អភិវឌ្ឍ។

***បញ្ហាប្រឈម***

- កង្វះសាស្ត្រាចារ្យ និងថវិកា
- អង្គភាពមិនទាន់ជាអង្គភាពថវិកា
- ការពិបាកទាក់ទាញនិស្សិតបន្តការសិក្សារហូតបញ្ចប់បរិញ្ញាបត្រ។

**៣.២.១៤.ការពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំនិងការស្រាវជ្រាវលើផ្នែកអប់រំបច្ចេកទេស និងវិជ្ជាជីវៈ (វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ)**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ២៥ភាគរយ អាចទទួលយកបាន ៣ ស្មើ ៧៥ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***

- ការកែលម្អកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររងឱ្យស្របតាមទីផ្សារការងារនាពេលបច្ចុប្បន្ន
- ការវាយតម្លៃគុណភាពការបង្រៀនរបស់បុគ្គលិកអប់រំ
- ការអនុវត្តស្រាវជ្រាវ០៦ គម្រោង
- ការចុះអនុស្សរណៈ០៣ ជាមួយបរទេស។

***បញ្ហាប្រឈម***

- ការពិបាកក្នុងការប្រើប្រាស់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ( នីតិវិធីស្មុគស្មាញ)
- កង្វះទឹកស្អាត និងអន្តេវាសិកគ្រូ និងនិស្សិត។

**៣.២.១៥. លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំគ្រូបង្រៀនឆ្លើយស្របតាម លក្ខខណ្ឌគុណវុឌ្ឍិជាតិ (វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ)**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ ៥ ស្មើ ១០០ភាគរយ អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***

- ការបង្កើតប្រព័ន្ធគ្រប់គ្រងការងារ និងការសិក្សាតាមបែបឌីជីថល ដើម្បីផ្តល់ភាពងាយស្រួលដល់មន្ត្រីគ្រប់គ្រងអប់រំ គ្រូឧទ្ទេស គរុនិស្សិត និងអតីតគរុនិស្សិតបន្ត ចែករំលែកឯកសារ បទពិសោធ ដែលជាផ្នែកមួយបន្តគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពជាប្រចាំដល់គ្រូបង្រៀន
- ការវាយតម្លៃតាមប្រព័ន្ធ GPA ជំរុញលើកកម្ពស់ស្វ័យសិក្សា និងការសិក្សាស្រាវជ្រាវរបស់គរុនិស្សិត។

***បញ្ហាប្រឈម***

- កង្វះមន្ត្រីកិច្ចសន្យា
- អង្គភាពមិនទាន់ក្លាយជាអង្គភាពថវិកា។

**៣.២.១៦. ពង្រឹងគុណភាពបណ្តុះបណ្តាលវិក្រឹតការគ្រូនិងការស្រាវជ្រាវស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ (វិទ្យាស្ថានគរុកោសល្យបាត់ដំបង)**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ ៥ ស្មើ ១០០ភាគរយ អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- ការចុះធ្វើថ្នាក់សង្កេត ថ្នាក់និទស្សន៍ និងការធ្វើកម្មសិក្សាគរុកោសល្យ។

*បញ្ហាប្រឈម*

- អង្គភាពមិនទាន់ជាអង្គភាពថវិកា និងកង្វះមន្ត្រីជំនាញហិរញ្ញវត្ថុ។

**រូបភាពទី ៧ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករតាមអនុកម្មវិធីក្នុងកម្មវិធីទី២**




**៣.៣ កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា**

**៣.៣.១. ការអភិវឌ្ឍកីឡាមហាជន**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ ១ ស្មើ ១០០ភាគរយ។

*ផលសម្រេច*

- ការអភិវឌ្ឍសមត្ថភាពសហព័ន្ធកីឡា
- ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាស៊ីហ្គេម។

*បញ្ហាប្រឈម*

**៣.៣.២. ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស-និស្សិត**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ១ ស្មើ ៥០ភាគ

រយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ។

***ផលសម្រេច***

- ការអភិវឌ្ឍសមត្ថភាព គ្រូឧទ្ទេសក្នុងការប្រើប្រាស់សៀវភៅមុខវិជ្ជាអប់រំកាយ
- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ សាលាតម្រង់ទិសវិទ្យាល័យមួយទីលានកីឡាបាល់ទាត់
- ការចេញសេចក្ដីណែនាំការអនុវត្តកម្មវិធីអប់រំកាយក្នុងម៉ោងសិក្សា និងកីឡា ក្រៅម៉ោងសិក្សា។

***បញ្ហាប្រឈម***

- ការអនុវត្តសកម្មភាពអប់រំកាយ និងកីឡាមិនឆ្លើយតបក្របខណ្ឌកម្មវិធីសិក្សា។

**៣.៣.៣. ការបណ្ដុះបណ្ដាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ។

***ផលសម្រេច***

- បណ្ដុះបណ្ដាលគរុសិស្ស ជំនាន់ទី៣០ ឆ្នាំទី១ ចំនួន១១៤នាក់ ស្រី៣៩នាក់ និស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី២ ចំនួន ២៥នាក់ ស្រី០២នាក់ និងបរិញ្ញាបត្រជំនាន់ទី៣ ចំនួន ២២នាក់ ស្រី ០៨នាក់ និងបានធ្វើការប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាន់ទី១ ចំនួន ២០នាក់ ស្រី០០នាក់។

***បញ្ហាប្រឈម***

- ក្របខណ្ឌពេលវេលា។

**៣.៣.៤. ការអភិវឌ្ឍកីឡាកម្រិតខ្ពស់**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ១០០ភាគរយ អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***

- ការអភិវឌ្ឍសមត្ថភាព កីឡាករ កីឡាការិនីជម្រើសជាតិក្នុងប្រព័ន្ធ។

***បញ្ហាប្រឈម*** (គ្មាន)

**៣.៣.៥. ការអភិវឌ្ឍការប្រកួត និងគ្រប់គ្រងព្រឹត្តិការណ៍កីឡាគ្រប់កម្រិត**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ (អនុវត្តពីរឆ្នាំម្ដង)។

***ផលសម្រេច***

- ការពង្រឹងគុណភាពនៃការរៀបចំ និងគ្រប់គ្រងព្រឹត្តិការណ៍កីឡា
- ការអភិវឌ្ឍសមត្ថភាពមន្ត្រីអំពីការរៀបចំ និងគ្រប់គ្រងព្រឹត្តិការណ៍។

***បញ្ហាប្រឈម*** (គ្មាន)

**៣.៣.៦. ការអភិវឌ្ឍផ្នែកព័ត៌មាន និងស្ថិតិកីឡាគ្រប់ប្រភេទ**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ។

***ផលសម្រេច***

- ការបំប៉នសមត្ថភាពមន្ត្រីអំពីការប្រើប្រាស់ព័ត៌មានវិទ្យាកម្រិត២ សម្រាប់ ស្រង់ទិន្នន័យ និងស្ថិតិកីឡា

- ការផលិតទស្សនាវដ្ដីកីឡា និងចងក្រងឯកសារកីឡា។

***បញ្ហាប្រឈម***

- កិច្ចដំណើរការឯកសារថវិកាច្រើនដំណាក់កាល និងយឺតយ៉ាវ
- មន្ត្រីជំនាញផ្នែកប្រព័ន្ធព័ត៌មានវិទ្យាសមត្ថភាពនៅមានកម្រិត
- កង្វះមន្ត្រី សម្ភារៈ និងកញ្ចប់ថវិកានៅមានកម្រិតខ្លាំង។

**រូបភាពទី ៨ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករតាមអនុកម្មវិធីក្នុងកម្មវិធីទី៣**




## ៣.៤ កម្មវិធីទី៤៖ ការអភិវឌ្ឍជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់យុវជន

### ៣.៤.១. ការអភិវឌ្ឍសកម្មភាពយុវជន

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ៥0ភាគរយ អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ ១ ស្មើ ៥0ភាគរយ។

***ផលសម្រេច***

- ការផលិតវីដេអូអប់រំខ្លះស្តីពីយុវជនសតវត្សទី២១
- ការរៀបចំប្រឡងប្រណាំងស្នាដៃយុវជនសតវត្សទី២១
- ការរៀបចំកម្មវិធីការជជែកដេញដោលយុវជនថ្នាក់ជាតិ
- ការរៀបចំកម្មវិធី Bootcamp ( យុវជន២១ )
- កម្មវិធីផ្លាស់ប្តូរបទពិសោធន៍ក្នុង និងក្រៅប្រទេស
- វគ្គបំប៉នសមត្ថភាពស្តីពី ការយល់ដឹងអំពីធុរកិច្ច (KAB)។

***បញ្ហាប្រឈម***

- ការផ្លាស់ប្តូរសមាសភាពមន្ត្រីហិរញ្ញវត្ថុ ដែលធ្វើអោយការគ្រោងថវិកាអនុវត្តកម្មវិធីមានភាពយឺតយ៉ាវ
- គោលការណ៍ណែនាំទូទាត់ថវិកា នៃការអនុវត្តកម្មវិធី តាមប្រព័ន្ធអនឡាញមិនទាន់មានភាពច្បាស់លាស់។

### ៣.៤.២. ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ២ ស្មើ ១00 ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***

- ការអនុវត្តកម្មវិធីសមមូលកម្រិតមូលដ្ឋានតាមអ៊ីនធឺណែតបឹបនិងអក្ខរកម្មឌីជីថល

- វគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់បំណិនជីវិត និងវិជ្ជាជីវៈ។

*បញ្ហាប្រឈម*

- កង្វះមន្ត្រីរដ្ឋបាល និងបច្ចេកវិទ្យាព័ត៌មានវិទ្យា។

**៣.៤.៣. ការអភិវឌ្ឍកាយវប្បកម្ម**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ ១ ស្មើ ១០០ភាគរយ។

*ផលសម្រេច*

- ការពង្រឹងជីវភាពប្រព័ន្ធកងល្បាតដល់កុមារ និងយុវជននៅតាមសាលារៀន តាមរយៈការអនុវត្តគោលការណ៍ ការសច្ចាប្រណិធាន និងច្បាប់កាយវប្បទ្ធិ ដើម្បីអភិវឌ្ឍកម្មវិធីសម្រាប់កុមារ និងយុវជនឱ្យមាន "វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា"ជាពិសេសបំណិនសតវត្សទី២១ ឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្ម៤.០ និងបរិវត្តកម្មឌីជីថល។

*បញ្ហាប្រឈម*

- កង្វះគ្រឿងឥស្សរិយយសកាយវប្បទ្ធិ និងបណ្ណសញ្ញាវឌ្ឍនកម្មកាយវប្បទ្ធិ
- កង្វះមន្ត្រីជំនាញកាយវប្បទ្ធិកម្មនៅតាមគ្រឹះស្ថានសិក្សា។

**រូបភាពទី ៩ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករតាមអនុកម្មវិធីក្នុងកម្មវិធីទី៤**




**៣.៥ កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ**

**៣.៥.១. ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងប្រព័ន្ធផែនការអប់រំ**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ២ ស្មើ ៤០ភាគរយ និងមិនសម្រេចចំណុចដៅ ៣ ស្មើ ៦០ភាគរយ។

*ផលសម្រេច*

- ការរៀបចំក្របខណ្ឌការងារផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២៨ ថ្នាក់ជាតិ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ
- ការរៀបចំក្របខណ្ឌការងាររៀបចំរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤
- ការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មរវាង ១)ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២) អ្នកគ្រប់គ្រងកម្មវិធី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២៤-២០២៦។

*បញ្ហាប្រឈម*

- កង្វះមន្ត្រីបច្ចេកទេសកសាងផែនការអប់រំ
- កង្វះមន្ត្រីផ្នែកបច្ចេកវិទ្យាព័ត៌មាន។

**៣.៥.២. ការគ្រប់គ្រង និងពង្រឹកប្រសិទ្ធភាពធនធានមនុស្ស**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ២ ស្មើ ៦៦,៦៧ភាគរយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ៣៣,៣៣ ភាគរយ។

*ផលសម្រេច*

- ការអភិវឌ្ឍវិជ្ជាជីវៈផ្សាភ្ជាប់ជាមួយ HRMIS និងគន្លងអាជីពគ្រូបង្រៀន
- ការរៀបចំម៉ោងបន្ថែមនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ១៣ និងសាលាអនុវត្តន៍ ១៣។

*បញ្ហាប្រឈម*

**៣.៥.៣. ការអភិវឌ្ឍសមត្ថភាព ការងារគ្រប់គ្រង ផែនការហិរញ្ញវត្ថុ និងមូលដ្ឋានសម្ភារៈ**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ។

*ផលសម្រេច*

- ការផ្តល់ថវិកាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូសម្រាប់ចំណាយលើកិច្ចដំណើរការរៀន បង្រៀននិងការស្រាវជ្រាវ
- ការផ្តល់ថវិកាសម្រាប់បំប៉ន សិស្សពូកែ ការបោះពុម្ពឯកសារ និងសម្ភារៈសម្រាប់កិច្ចការប្រឡង។

*បញ្ហាប្រឈម*

- ឥណទានថវិការបស់ក្រសួងមិនទាន់ឆ្លើយតបទៅនឹងសូចនាករគោលដៅ ២០%នៃចំណាយចរន្តថ្នាក់ជាតិ
- ចំណាយក្រៅបន្ទុកបុគ្គលិកមិនទាន់ឆ្លើយតបទៅនឹងសូចនាករគោលដៅយ៉ាងតិច២២% នៃថវិការួមរបស់ក្រសួងសម្រាប់ចំណាយលើការអភិវឌ្ឍសមត្ថភាពនិងស្ថាប័ន
- ការកំណត់ពិតានគោលនៅក្នុងសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP)
- ការសម្រួចផែនការសកម្មភាពអាទិភាពមិនទាន់ឆ្លើយតបទៅនឹងពេលវេលានៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ
- អង្គភាពដែលមានចរិកលក្ខណៈជាអង្គភាពគាំទ្រពិបាកក្នុងការវិភាជថវិកាតាមអនុវិស័យនិងចំណាត់ថ្នាក់មុខងារ
- ចំនួនអង្គភាពថវិកាច្រើន និងរចនាសម្ព័ន្ធនៃអង្គភាពថវិកានីមួយៗ ខុសប្លែកគ្នា ( កម្រិតនាយកដ្ឋាន វិទ្យាស្ថាន សាកលវិទ្យាល័យ និងកម្រិតអគ្គនាយកដ្ឋាន)
- មិនអាចបូកសរុបថវិការបស់ការិយាល័យ អ.យ.ក នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងមិនបានរំលេច នូវថវិកាអប់រំ ដាច់ដោយឡែកពីអនុវិស័យផ្សេងៗនៃសៀវភៅថវិកានៅថ្នាក់ក្រោមជាតិ
- ការផ្តល់ថវិកាប្រជុំបច្ចេកទេសដល់សាលារៀន និងថវិកាដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍មិនទាន់ស្របតាម ប្រកាស៥០៨ សហវ.ប្រក ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី នៅក្រសួងអប់រំ យុវជន និងកីឡា
- ការយល់ដឹងរបស់សាលារៀនសាធារណៈ នៃការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងមូលនិធិដំណើការសាលារៀននៅមានកម្រិត
- អង្គភាពថវិកាមួយចំនួនមានការផ្លាស់ប្តូររដ្ឋទេយ្យករនិងរដ្ឋទេយ្យកររង

- ការអនុវត្តកិច្ចលទ្ធកម្មមានច្រើនដំណាក់កាល និងប្រើប្រាស់ពេលវេលាច្រើន
- អង្គភាពអនុវត្តមូលនិធិ CDPF មួយចំនួនមិនបានផ្តល់របាយការណ៍ទូទាត់មកនាយកដ្ឋានហិរញ្ញវត្ថុទាន់ពេលវេលា និង បណ្តាលឱ្យការបំពេញទិន្នន័យរបាយការណ៍ទូទាត់ទៅក្នុងប្រព័ន្ធគណនេយ្យ SAGE ៥០ មិនបានពេញលេញ
- គម្រោងមួយចំនួន មិនបានផ្តល់របាយការណ៍ហិរញ្ញវត្ថុតាម COA ប្រចាំឆ្នាំ២០២២ មកការិយាល័យទាន់ពេល វេលា ដូចបានកំណត់ក្នុងលិខិតជូនដំណឹង។ គម្រោងដែលមិនទាន់បានផ្តល់របាយការណ៍មកការិយាល័យមានដូចជាៈ គម្រោង SEIP, គម្រោងសាងសង់និងជួសជុលសាលាបឋមសិក្សានិងមធ្យមសិក្សានៅទូទាំងប្រទេសជំហានទី១, គម្រោងសាងសង់ និងជួសជុលសាលាបឋមសិក្សា និងមធ្យមសិក្សានៅទូទាំងប្រទេសជំហានទី២, និងគម្រោងកែលម្អបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារអប់រំនៅកម្ពុជា។

### ៣.៥.៤. ការពង្រឹងការងារសវនកម្មផ្ទៃក្នុង

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ៣ ស្មើ ៦០ភាគរយ និងមិនសម្រេចចំណុចដៅ ២ ស្មើ ៤០ភាគរយ។

***ផលសម្រេច***

- ការធ្វើសវនដ្ឋាន៦៥ អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- ការចុះសវនកម្មបច្ចេកវិទ្យាព័ត៌មាននៅ មន្ទីរអេយក.ចំនួន១ សាលាចំណោះទូទៅចំនួន៥
- ការចុះសវនកម្មសមិទ្ធកម្មសាកល្បង នៅមន្ទីរអេយក.ចំនួន១
- ការបណ្តុះបណ្តាលមន្ត្រីសវនកម្មផ្ទៃក្នុង ៤៦ នាក់ ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ។

***បញ្ហាប្រឈម***

- មន្ត្រីសវនកម្មផ្ទៃក្នុង មិនទាន់ឆ្លើយតបទៅនឹងការធ្វើសវនកម្មសមិទ្ធកម្ម ប្រព័ន្ធព័ត៌មានវិទ្យា និងសវនកម្មគម្រោង ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ
- ការអនុវត្តវិធីសាស្ត្រ និងនីតិវិធីសវនកម្មផ្ទៃក្នុងមិនទាន់ឆ្លើយតបទៅនឹងស្តង់ដាសវនកម្មផ្ទៃក្នុងនៅឡើយ។

### ៣.៥.៥. ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ចគុណភាពអប់រំ

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ៥ ស្មើ ១០០ ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***

- អធិការកិច្ចតាមប្រធានបទស្តីពីការអនុវត្តកម្មវិធីសិក្សាលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និង រូបវិទ្យា ថ្នាក់ទី៨
- ការផ្សព្វផ្សាយរបាយការណ៍អធិការកិច្ចតាមកាលកំណត់ទាំង២៥រាជធានី ខេត្ត
- បំប៉នសមត្ថភាពស្តីពីការអនុវត្តតេស្តវាយតម្លៃដែលមានលក្ខណៈស្តង់ដា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ
- ការពិគ្រោះយោបល់២លើកស្តីពី គម្រោងលម្អិតតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី១១
- ការផ្សព្វផ្សាយលទ្ធផលតេស្តវាយតម្លៃលទ្ធផលសិក្សាសិស្សបឋមសិក្សា នៅតំបន់អាស៊ីអាគ្នេយ៍ឆ្នាំ២០១៩ និងការត្រៀមអនុវត្តតេស្តសាកល្បង(SEA-PLM)ឆ្នាំ២០២៣ ចំនួន២៥រាជធានី ខេត្ត
- ការកំណត់បានពីទិដ្ឋភាពទូទៅនៃកម្មវិធី PISA ឆ្នាំ២០២២ លទ្ធផលជាមេរៀនពិសោធន៍ល្អៗ បញ្ហា

ប្រឈម សំណូមពរ និងផែនការបន្ទាប់ នៃការអនុវត្តកម្មវិធី PISA-២០២២

- ការបំប៉នសមត្ថភាពស្តីពីបច្ចេកទេសអនុវត្តតេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង(EGMA) ។

*បញ្ហាប្រឈម*

- កង្វះថវិកាអធិការកិច្ច និងកង្វះកុំព្យូទ័រយួរដៃ។

**៣.៥.៦. អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ២ ស្មើ ៥០គរយ និងមិនសម្រេចចំណុចដៅ ២ ស្មើ ៥០ភាគរយ។

*ផលសម្រេច*

- ការអនុវត្តតាមប្រកាសលេខ២២៨០អយក.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ស្តីពីនីតិវិធីនៃការស្នើឬការតវ៉ាការប្តឹង និងដំណោះស្រាយសម្រាប់អ្នកសិក្សា មាតាបិតាឬអាណាព្យាបាល និងបុគ្គលិកអប់រំ
- ការដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីអធិការកិច្ចការគ្រប់គ្រងបុគ្គលិក រដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ បោះពុម្ពឆ្នាំ២០១៧
- ការដាក់ឱ្យប្រើប្រាស់សៀវភៅកម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គលិក រដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ បោះពុម្ពឆ្នាំ២០១៨
- ការអនុវត្តតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ បោះពុម្ពឆ្នាំ ២០១៨ ដែលចាប់អនុវត្តពីឆ្នាំ២០១៩
- ការដាក់ឱ្យប្រើប្រាស់សៀវភៅកម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ បោះពុម្ពឆ្នាំ២០២១ ។

*បញ្ហាប្រឈម*

- ការដាក់ពាក្យបណ្តឹងតវ៉ាមិនតាមឋានានុក្រម
- កង្វះការបណ្តុះបណ្តាលមន្ត្រីជំនាញលើស្តង់ដាអធិការកិច្ចទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

**៣.៥.៧. លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអប់រំ និងកិច្ចសហប្រតិបត្តិការអាស៊ាន និងស៊ីមេអូ**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៥ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ២០ភាគរយ អាចទទួលយកបាន ២ ស្មើ ៤០ភាគរយ និងមិនសម្រេចចំណុចដៅ ២ ស្មើ ៤០ភាគរយ។

*ផលសម្រេច*

- ការផលិតផ្ទាំងរូបភាពស្តីពីចំណីអាហារហាមឃាត់ក្នុងគ្រឹះស្ថានសិក្សាចំនួន ១០០០ផ្ទាំង
- ការផ្សព្វផ្សាយតាមសាលារៀននានា តាមបណ្តាខេត្តមួយចំនួន
- ការផលិតវីដេអូ ១៨ ស្តីពី សមិទ្ធផលសម្រេចនៅស្រុកកងមាស រយៈពេល ១០ឆ្នាំ
- ផលិតសៀវភៅសមិទ្ធផលសម្រេចបាននៅក្នុងស្រុកកងមាស រយៈពេល ១០ឆ្នាំ
- ការបោះពុម្ពសៀវភៅចំនួន ៤០០ក្បាលស្តីពីកាអប់រំនៅកម្ពុជា ដែលកាសែតភ្នំពេញចុះមួយខែម្តង
- ការបណ្តុះបណ្តាលស្តីពីចំណេះដឹងអង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ (ស៊ីមេអូ)។

*បញ្ហាប្រឈម*

- កង្វះកាម៉ារ៉ា កុំព្យូទ័រកាត់ត សម្ភារបម្រើការថត មន្ត្រីមានជំនាញថត និងកាត់ត
- ការសហការពីអង្គភាពពាក់ព័ន្ធមិនទាន់បានប្រសើរ។

### ៣.៥.៨. ការពង្រឹងការងារនីតិកម្ម

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ២ ស្មើ ៦៦,៦៧ ភាគរយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ៣៣,៣៣ភាគរយ។

*ផលសម្រេច*

- ការផ្សព្វផ្សាយអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍
- ការផ្សព្វផ្សាយអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ស្តីពីការការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា
- ការដាក់ឱ្យអនុវត្តប្រកាសលេខ៣២០ អយក.ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគាធនជាន
- ការដាក់ឱ្យអនុវត្តប្រកាសលេខ៤៧៩ អយក.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការបង្កើតការិយាល័យប្រឡងនៅតាមមន្ទីរ អប់រំ យុវជន និងកីឡា
- ការដាក់ឱ្យអនុវត្តប្រកាសលេខ៤៨៦ អយក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះលេខាលេខាធិការដ្ឋានគណៈកម្មាធិការប្រឆាំងដូប៉ានៃកម្ពុជា
- ការផ្សព្វផ្សាយអនុក្រឹត្យលេខ៩២ អនក្រ.បក ចុះនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រប់គ្រង
- ការផ្សព្វផ្សាយអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ការផ្សព្វផ្សាយអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានសិក្សាអន្តរជាតិនិងគោលនយោបាយសាធារណៈ។

*បញ្ហាប្រឈម*

- ការគ្រោងផែនការនៅក្នុង BSP និង AOP មានការខុសគ្នាដោយសារមានកំហុសនៅពេលគ្រោងរបស់ការិយាល័យតាមប្រព័ន្ធ បណ្តាលឱ្យមានការប្រែប្រួលថវិកាតាមចង្កោមនៅពេលបង្កើត AOP ចុងក្រោយ។

### ៣.៥.៩. ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ១ ស្មើ ៣៣,៣៣ភាគរយ និងមិនសម្រេចចំណុចដៅ ២ ស្មើ ៦៦,៦៧ ភាគរយ។

*ផលសម្រេច*

- ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងគុណភាពគ្រូឧទ្ទេស
- ការកែលម្អធនធានសិក្សា និងហេដ្ឋារចនាសម្ព័ន្ធ។

*បញ្ហាប្រឈម*

- កង្វះមន្ត្រីជំនាញ ព័ត៌មានវិទ្យា ស្ថាបត្យករ ភាសាអង់គ្លេស សម្ភារៈការិយាល័យ និងមធ្យោបាយធ្វើដំណើរ
- កង្វះថវិកាតាមការស្នើសុំរបស់ខេត្តក្រុង និងនីតិការទូទាត់ស្មុគស្មាញប្រើពេលយូរ។

### ៣.៥.១០. ការពង្រឹងការគ្រប់គ្រង ការផ្គត់ផ្គង់សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ១០០ភាគរយ អាចទទួលយកបាន

គ្មាន និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***

- ការអនុវត្តន៍នីតិវិធីជម្រះចេញពីបញ្ជីសារពើភណ្ឌនូវ៖អគារ សរុប ១១៣ខ្នង រថយន្ត សរុប ១២គ្រឿង ម៉ូតូ សរុប ១៨៥គ្រឿង និងគ្រឿងចក្រផ្សេងៗ សរុប ៥៦គ្រឿង
- ការធ្វើបច្ចុប្បន្នភាពទិន្នន័យយានយន្តរបស់អង្គភាពថ្នាក់កណ្តាល ថ្នាក់នីតិបុគ្គលសាធារណៈ និងថ្នាក់មូលដ្ឋានរួមមាន៖ រថយន្ត ចំនួន ៤៧៥គ្រឿង ម៉ូតូចំនួន ២ ១៤៩គ្រឿង ម៉ាស៊ីនភ្លើង ចំនួន ២៧៤គ្រឿង និងផ្សេងៗចំនួន ២៨៧គ្រឿង (ម៉ាស៊ីនបូមទឹក ១៥៣គ្រឿង ម៉ាស៊ីនកាត់ស្មៅ ៤៧គ្រឿង គោយន្ត ១៤គ្រឿង (អង្គភាពថ្នាក់កណ្តាល១) ត្រាក់ទ័រ ៨គ្រឿង កាណូត ៣៤គ្រឿង ម៉ាស៊ីនបោះពុម្ព កាត់និងកឹប ១៦គ្រឿង អេឡេវ៉ាទ័រ ១៥គ្រឿង)។

***បញ្ហាប្រឈម***

- ការប្រើប្រាស់ប្រព័ន្ធ SARMIS សម្រាប់ថ្នាក់មូលដ្ឋាន នៅមានកម្រិត
- ការចូលរួមឆ្លងបញ្ជីសារពើភណ្ឌអន្តរក្រសួងដើម្បីបំពេញនីតិវិធីនៅមានកម្រិត។

**៣.៥.១១. ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាភាពស័ក្តិសិទ្ធនៃសេវារដ្ឋបាលអប់រំ**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៤ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ២៥ភាគរយ អាចទទួលយកបាន ១ ស្មើ ២៥ភាគរយ និងមិនសម្រេចចំណុចដៅ ២ ស្មើ ៥០ភាគរយ។

***ផលសម្រេច***

- ការរៀបចំប្រារព្ធពិធីសន្និបាតអប់រំ យុវជន និងកីឡា។

***បញ្ហាប្រឈម*** (គ្មាន)

**៣.៥.១២. ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិលើវិស័យអប់រំ**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ១ ស្មើ ១០០ ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***

- ការលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអប់រំ និងកិច្ចសហប្រតិបត្តិការអាស៊ាន និងស៊ីមេអូ។

***បញ្ហាប្រឈម***

- ការទម្លាក់ថវិកាមិនទាន់ពេលវេលាអនុវត្ត នីតិវិធីស្មុគស្មាញ
- ក្រុមការងារថ្មីអនុវត្តនីតិវិធីការងារមិនល្អទូ។

**៣.៥.១៣. ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ**

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ ២ ស្មើ ១០០ភាគរយ អាចទទួលយកបាន គ្មាន និងមិនសម្រេចចំណុចដៅ គ្មាន។

***ផលសម្រេច***

- ការអភិវឌ្ឍកម្មវិធីមូលដ្ឋានទិន្នន័យអប់រំ
- ការប្រមូល និងកែច្នៃទិន្នន័យអប់រំ វិភាគទិន្នន័យ និងចងក្រងស្ថិតិអប់រំ
- ការបោះពុម្ព និងផ្សព្វផ្សាយស្ថិតិ និងសូចនាករអប់រំសម្រាប់ពិនិត្យតាមដានវាយតម្លៃ និងធ្វើការអភិវឌ្ឍវិស័យអប់រំ

- ការបំប៉នការងារស្ថិតិអប់រំដល់មន្ត្រីស្ថិតិគ្រប់លំដាប់ថ្នាក់
- ការពង្រឹងវិមជ្ឈការលើប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រហូតដល់សាលារៀន
- ការធ្វើបច្ចុប្បន្នកម្មស្ថិតិអប់រំ វិភាគ និងផលិតស្ថិតិ សូចនាករអប់រំ និងបោះពុម្ពផ្សព្វផ្សាយជាសាធារណៈ
- ការរៀបចំផែនទីសិក្សា និងផ្សព្វផ្សាយប្រើប្រាស់ជាសាធារណៈ។

*បញ្ហាប្រឈម*

- កង្វះមន្ត្រីបច្ចេកទេសផ្នែក ICT & AI ដើម្បីធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យថ្មី(EMIS, QEMIS, SDS, SRC &STS)ជំនាញផ្នែក ICT & AI មន្ត្រីក្រុមការងារផ្នែក IT & AI ព្រមទាំងកង្វះមន្ត្រីផែនការ និងស្ថិតិ។

**៣.៥.១៤. ការស្រាវជ្រាវ និងអភិវឌ្ឍគោលនយោបាយអប់រំ**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ និងមិនសម្រេចចំណុចដៅ ១ស្មើ ៥០ភាគរយ។

*ផលសម្រេច*

- ការផ្សព្វផ្សាយក្របខណ្ឌគោលនយោបាយគន្លងអាជីពគ្រូបង្រៀនដល់ភាគីពាក់ព័ន្ធនៅសាលាបណ្តាញ
- បញ្ចប់ឯកសារទស្សនទានលើប្រធានបទស្រាវជ្រាវស្តីពីគម្លាតសមត្ថភាពសិក្សារវាងសិស្សប្រុស និងសិស្សស្រីនៅកម្រិតមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ
- ការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវថ្នាក់តំបន់ស្តីពីការបាត់បង់ការសិក្សាលើ ផ្នែកអំណាន និងគណិតវិទ្យារបស់សិស្សនៅកម្រិតបឋមសិក្សាអំឡុងពេលរីករាលដាល នៃ ជំងឺកូវីដ-១៩ ក្នុងតំបន់អាស៊ាន
- ការរៀបចំសេចក្តីព្រាងសៀវភៅណែនាំប្រតិបត្តិស្តីពីសាលារៀនមានប្រសិទ្ធភាព។

*បញ្ហាប្រឈម*

- លំហូរថវិកាយឺតមិនទាន់ការអនុវត្តសកម្មភាព
- ការកំណត់ប្រធានបទស្រាវជ្រាវគោលនយោបាយយឺតធ្វើឱ្យការសិក្សាស្រាវជ្រាវខ្លី។

**៣.៥.១៥. ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ២ ក្នុងនោះសម្រេចចំណុចដៅ ១ ស្មើ ៥០ភាគរយ អាចទទួលយកបាន ១ ស្មើ ៥០ភាគរយ និងមិនសម្រេចចំណុចដៅ គ្មាន។

*ផលសម្រេច*

- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធ គោលការណ៍ និងទម្រង់របាយការណ៍សមិទ្ធកម្ម
- ការរៀបចំរបាយការណ៍សន្និបាតអប់រំ យុវជន និងកីឡា
- ការរៀបចំរបាយការណ៍សមិទ្ធកម្មថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រចាំត្រីមាសទី១ និងទី២
- ការរៀបចំក្របខណ្ឌថវិកាសមិទ្ធកម្មថ្នាក់ជាតិ
- ការរៀបចំរបាយការណ៍វិភាគស្តីពីការអនុវត្តគម្រោងស្បៀងអាហារតាមសាលរៀនគោលដៅ។

*បញ្ហាប្រឈម*

- កង្វះមន្ត្រីជំនាញបច្ចេកវិទ្យាព័ត៌មាន ថវិកា និងពេលវេលា ។

**៣.៥.១៦. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ការងារអប់រំ យុវជន និងកីឡា**

*សូចនាករ*

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ៣ ក្នុងនោះសម្រេចចំណុចដៅ គ្មាន អាចទទួលយកបាន ២ ស្មើ ៦៦,៦៧ ភាគរយ និងមិនសម្រេចចំណុចដៅ ១ ស្មើ ៣៣,៣៣ ភាគរយ។

***ផលសម្រេច***

- ការងារចុះពិនិត្យតាមដាន និងផ្តល់ជំនួយបច្ចេកទេស
- ការថែទាំ និងធានាដំណើការម៉ាស៊ីន
- ការជួយគាំទ្រប្រព័ន្ធវីដេអូសន្និសីទ
- វគ្គបណ្តុះបណ្តាលផ្ទាល់ ៣៧វគ្គ និងតាមអនឡាញ១៥ វគ្គ
- ការរៀបចំកម្មវិធី Technovation ២០២៣
- ការផ្សាយកម្មវិធីតម្រង់ទិសការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំមុខវិជ្ជាបំណិនជីវិតមូលដ្ឋាន
- ការផ្សព្វផ្សាយព័ត៌មានតាមគេហទំព័រ និងបណ្តាញសង្គមក្រសួង
- ការផ្សាយកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន និងកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ
- ការផលិតវីដេអូ ការបង្កើតបណ្តាញ Youtube: www.youtube.com/moeyscambodia និងការបង្កើតកម្មវិធី
- MoEYS E-Learning Apps។

***បញ្ហាប្រឈម*** (គ្មាន)

### ៣.៥.១៧ អនុកម្មវិធីទី៥.១៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សានិងអប់រំបច្ចេកទេស

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ (វាយតម្លៃលទ្ធផលសម្រេចនៅចុងឆ្នាំ)។

***ផលសម្រេច***

- ការរៀបចំការប្រឡងមធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ សិស្សពូកែទូទាំងប្រទេសលើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា និង ភាសាខ្មែរ និងការប្រឡងសិស្សពូកែអូឡាំព្យាដក្នុងប្រទេសដើម្បីចូលរួមការប្រកួតនៅក្រៅប្រទេស
- ការបំប៉នសិស្សឆ្នើម(គណិតវិទ្យា និង រូបវិទ្យា)។

***បញ្ហាប្រឈម***

- កង្វះថវិកាអនុវត្តសកម្មភាព។

### ៣.៧.១៨ ការងារមជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស

***សូចនាករ***

- សូចនាករលទ្ធផលក្នុងឆ្នាំ សរុប ១ (វាយតម្លៃលទ្ធផលសម្រេចនៅចុងឆ្នាំ)។

***ផលសម្រេច***

- ការពង្រឹងសមត្ថភាពគ្រូផ្នែកអប់រំបច្ចេកទេស គណៈគ្រប់គ្រងវិទ្យាចំណេះទូទៅ និងបច្ចេកទេស និងមន្ត្រីអប់រំ ដែលគាំទ្រការងារផ្នែកអប់រំបច្ចេកទេស
- ការស្រាវជ្រាវដើម្បីបង្កើតលិខិតបទដ្ឋានគតិយុទ្ធគាំទ្រដូចជាគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងសេចក្តីណែនាំ
- ការពង្រឹងកិច្ចសហប្រតិបត្តិការចុះអនុស្សរណៈសហការៀបចំព្រឹត្តិការណ៍ធំៗរួមគ្នា។

***បញ្ហាប្រឈម***

- កង្វះមន្ត្រីសមត្ថភាពការងារស្រាវជ្រាវ

- កង្វះនាយករងមួយរូបជួយការងារផ្នែកកម្មវិធី (ការងារថ្នាក់តំបន់)
- កង្វះថវិកាអនុវត្តសកម្មភាពតំបន់។

**រូបភាពទី ១០ ៖ វឌ្ឍនភាពនៃការសម្រេចសូចនាករតាមអនុកម្មវិធីក្នុងកម្មវិធីទី៥**




## ៤. សេចក្តីសន្និដ្ឋាន

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តនូវមុខងារ ភារកិច្ច និងតួនាទីរបស់អង្គភាពដែលអនុវត្តថវិកាថ្នាក់ជាតិ ប្រកបដោយការទទួលខុសត្រូវខ្ពស់ សំដៅធានាឱ្យទទួលបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងផលសម្រេចបានស្របតាមគោលនយោបាយកំណែទម្រង់អាទិភាពថវិកាសមិទ្ធកម្ម និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ សមិទ្ធកម្មនៃការអនុវត្តផែនការប្រតិបត្តិប្រចាំប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ ពិតជាបានបង្ហាញពីការខិតខំរបស់អង្គភាពនៅកម្រិតថ្នាក់ជាតិក្នុងភាពជាម្ចាស់ក្នុងការអភិវឌ្ឍក្របខណ្ឌការងារ ក្របខណ្ឌច្បាប់ ឯកសារគតិយុត្តសម្រាប់ការគាំទ្រ និងការបង្កើតកម្មវិធីឬគម្រោងនានា ដើម្បីអភិវឌ្ឍសមត្ថភាពនៃការអនុវត្តសកម្មភាពដែលបានគ្រោងទុកក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ និងការងារពិនិត្យតាមដាន និងវាយតម្លៃនៅកម្រិតមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងសាលារៀនផងដែរ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឧបសម្ព័ន្ធ ៖ វឌ្ឍនភាព សូចនាករហិរញ្ញវត្ថុ សូចនាករសមិទ្ធកម្ម
## (តាមជានការអនុវត្ត កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព)

| | |
|---|---|
| គោលបំណងគោលនយោបាយ | គ.ប.ទី១៖ ធានាឱ្យមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា។<br>គ.ប.ទី២៖ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់។ |
| ឥណទានថវិការបស់ក្រសួង | លានរៀល |

| ឈ្មោះ អនុកម្មវិធី / ចង្កោមសកម្មភាព/ សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករហិរញ្ញវត្ថុ | | | សូចនាករសមិទ្ធកម្ម | | | | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តប្រចាំឆមាសទី១ | %ចំណាយ | គោលដៅប្រចាំឆ្នាំ | អនុវត្តប្រចាំឆមាសទី១ | %នៃគោលដៅ | ស្ថានភាព | | |
| **សរុបចំណាយថវិកាកម្មវិធី** | 3,361,825.7 | | | | | | | | |
| **កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធក្រៅប្រព័ន្ធ និងមិនផ្លូវការ** | 307,384.0 | 42,072.6 | | | | | | | |
| សូចនាករលទ្ធផលចុងក្រោយ១.១៖ អត្រាចូលរៀនកុមារអាយុ៥ឆ្នាំគ្រប់រូបភាព (មត្តេយ្យសិក្សារដ្ឋ សហគមន៍ និងឯកជន) | | | | 63.1% | 64.8% | 102.7% | ↑ | | |
| សូចនាករលទ្ធផលចុងក្រោយ១.២៖ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | 88.7% | 86.8% | 97.9% | → | | |
| សូចនាករលទ្ធផលចុងក្រោយ១.៣៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | 53.1% | 55.7% | 104.9% | ↑ | | |
| សូចនាករលទ្ធផលចុងក្រោយ១.៤៖ អត្រាអក្ខរកម្មពេញវ័យ (អាយុ១៥ ឆ្នាំឡើង) | | | | 90.7% | 84.7% | 93% | → | លទ្ធផលឆ្នាំ២០២១ ចេញដោយក្រសួងផែនការ | |
| **អនុកម្មវិធី១.១៖ ការពង្រីកការអប់រំកុមារតូច (នាយកដ្ឋានអប់រំកុមារតូច)** | 12,799.5 | 1270.1 | 9.9% | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ក៖ អត្រាចូលរៀនកុមារអាយុ ៥ ឆ្នាំនៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងឯកជន | | | | 63.1% | 64.8% | 102.7% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ខ៖ អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាឯកជន | | | | 37.4% | 37.1% | 99.2% | → | | |
| **ចង្កោមសកម្មភាពទី១.១.១៖ ការគាំពារនិងការអភិវឌ្ឍកុមារតូច** | **12,475.0** | **1064.6** | 8.5% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.ក៖ ចំនួនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា | | | | 1350 | 1305 | 96.7% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.ខ៖ ចំនួនមត្តេយ្យសិក្សាបើកថ្មីនៅក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ | | | | 378 | 0 | 0 | ↓ | | |
| **ចង្កោមសកម្មភាពទី១.១.២៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអនុវិស័យអប់រំកុមារតូច** | **324.5** | 205.5 | 63.3% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.ក៖ ចំនួនសាលាមត្តេយ្យសិក្សាធនធាន សម្រេចបានតាមលក្ខណៈស្តង់ដា | | | | 4 | 0 | 0 | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.ខ៖ ចំនួនសាលាមត្តេយ្យសិក្សារដ្ឋ បានអនុវត្តការគ្រប់គ្រងសាលារៀនសម្រាប់មត្តេយ្យសិក្សា | | | | 213 | 213 | 100.0% | ↑ | | |
| **អនុកម្មវិធី១.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា (នាយកដ្ឋានអប់រំបឋមសិក្សា)** | 1,938.3 | 144.7 | 7.5% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.ក អត្រាពិតនៃការសិក្សា | | | | 93% | 93% | 100.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.ខ អត្រាត្រួតថ្នាក់ | | | | 5% | 7% | 71.4% | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.គ អត្រាបោះបង់ការសិក្សា | | | | 6% | 7% | 88.6% | → | | |
| **ចង្កោមសកម្មភាពទី១.២.១៖ ការអភិវឌ្ឍការអប់រំបឋមសិក្សាដើម្បីធានាឱ្យការចូលរៀនមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន** | 1,392.3 | 10.8 | 0.8% | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.១.ក ៖ ចំនួនបុគ្គលិកអប់រំបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែមលើវិធីសាស្ត្របង្រៀននិងបង្រៀន | | | | 10000 | 3401 | 34.0% | ↓ | | |
| **ចង្កោមសកម្មភាពទី១.២.២៖ ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំបឋមសិក្សា** | 546.0 | 133.9 | 24.5% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.២.ក៖ ចំនួនមន្ត្រីអប់រំបឋមសិក្សាបានទទួលការបំប៉នសមត្ថភាពលើការគាំទ្រការគ្រប់គ្រងតាមសាលារៀន | | | | 500 | 288 | 57.6% | → | | |
| **អនុកម្មវិធី១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ)** | 6,613.5 | 3683.8 | 55.7% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ក៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | 70.4% | 64.8% | 92.0% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ខ៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | 38.6% | 44.2% | 114.5% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.គ៖ អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ | | | | 84.7% | 83.7% | 98.8% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ឃ៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | 53.1% | 55.7% | 104.9% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ង៖ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | 14.1% | 17.2% | 122.0% | ↓ | | |
| **ចង្កោមសកម្មភាពទី១.៣.១៖ បង្កើនការចូលរៀននៅមធ្យមសិក្សា និង ជួយសិស្សរៀនមានសមត្ថភាពបញ្ញាល្អប្រសើរ និងរៀនចប់នៅមធ្យមសិក្សា** | 863.5 | 123.6 | 14.3% | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.កៈ ចំនួនភ្នាក់ងារផ្លាស់ប្តូរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកម្មវិធីការគ្រប់គ្រងតាមសាលារៀន | | | | ៤៥០ នាក់ | - | - | - | មិនទាន់ដល់ពេលអនុវត្ត | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.ខៈ ភាគរយបេក្ខជនប្រឡងជាប់សញ្ញាបត្រថ្នាក់ពីរភាសា បារាំង-ខ្មែរ | | | | បឋមភូមិ ៧៦,២% | - | - | - | មិនទាន់ដល់ពេលអនុវត្ត | |
| | | | | ទុតិយភូមិ ៨១,១% | - | - | - | មិនទាន់ដល់ពេលអនុវត្ត | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.គៈ ចំនួនសាលារៀនបានចុះជួយ (ពិនិត្យតាមដាន និងវាយតម្លៃ) | | | | 150 | 81 | 54.0% | → | | |
| **ចង្កោមសកម្មភាពទី១.៣.២៖ ការលើកកម្ពស់ការងារគ្រប់គ្រងថ្នាក់ជាតិ និងក្រោមជាតិ** | 5,750.0 | 3560.2 | 61.9% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.២.កៈ ចំនួនសាលារៀនជំនាន់ថ្មី | | | | ៧ សាលា | ៧ សាលា | 100.0% | ↑ | | |
| **អនុកម្មវិធី១.៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ (នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ)** | 1,955.0 | 1835.1 | 93.9% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.កៈ ប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | | | | ១២ ៦០០ នាក់ | ១ ៥៥០០ នាក់ | 123.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ខៈ សិស្សបានបញ្ចប់ថ្នាក់កម្មវិធីសមមូល | | | | ៧ ៤៨៧ នាក់ | ៣១០០ នាក់ | 41.4% | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.គៈ ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញនិងបានបញ្ជូនទៅក្នុងប្រព័ន្ធ | | | | ១០ ៤០០ នាក់ | 0 នាក់ | 0% | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ឃៈ ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាល ជំនាញមុខរបរសម្រាប់ការសិក្សាពេញមួយជីវិត (ម.ស.ស) | | | | ៩ ៤៩០ នាក់ | ៩ ៥០០ នាក់ | 100.1% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ងៈ ចំនួនមន្ត្រីអកបទទួលការបណ្តុះបណ្តាលសមត្ថភាពការគ្រប់គ្រងលើសេវាអកប | | | | ១៩០ នាក់ | 0 នាក់ | 0% | ↓ | | |
| **ចង្កោមសកម្មភាពទី១.៤.១៖ ការអភិវឌ្ឍការអប់រំក្រៅប្រព័ន្ធ** | 1,699.9 | 1680.0 | 98.8% | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ក៖ ចំនួនកម្មករ-កម្មការិនីដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមរោងចក្រសហគ្រាស | | | | ៥០០ នាក់ | ៤៥០ នាក់ | 90% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ខ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមសហគមន៍ ពន្ធនាគារ និងមណ្ឌលកែប្រែ | | | | ១២ ៣០០ នាក់ | ១៥ ០០០ នាក់ | 121.9% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.គ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលបឋមសិក្សា | | | | ៧ ១៨៧ នាក់ | ២ ៩០០ នាក់ | 40.4% | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ឃ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលមធ្យមសិក្សា | | | | ៣០០ នាក់ | ២០០ នាក់ | 66.7% | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ង៖ ចំនួនកុមារដែលបានបញ្ជូនចូលរៀនសាលាចំណេះទូទៅក្នុងប្រព័ន្ធ | | | | ១០ ៤០០ នាក់ | 0 | 0% | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ច៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរងាយៗ | | | | ៩ ៤៩០ នាក់ | 0 | 0% | ↓ | | |
| **ចង្កោមសកម្មភាពទី១.៤.២៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់** | 255.1 | 155.1 | 60.8% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.២.ក៖ ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ | | | | ១៣០ នាក់ | ២៥០ នាក់ | 192% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.២.ខ៖ ចំនួនស្រុកដែលអនុវត្តបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | | | | ៣០ ក្រុង ស្រុក | 28 | 93.3% | → | | |
| **អនុកម្មវិធី១.៥៖ ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា( នាយកដ្ឋានសុខភាពសិក្សា )** | 1,152.0 | 383.3 | 33.3% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ក៖ ភាគរយសាលារៀនអនុវត្តស្ដង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ១ (ចំណាត់ថ្នាក់ផ្កាយ ១) | | | | ៣៤% | - | - | - | អាចវាយតម្លៃនៅចុងឆ្នាំ | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ខ៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាត និងអនាម័យកម្រិត ២ (ចំណាត់ថ្នាក់ផ្កាយ ២) | | | | ៤៥% | - | - | - | អាចវាយតម្លៃនៅចុងឆ្នាំ | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.គ៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ៣ (ចំណាត់ថ្នាក់ផ្កាយ៣) | | | | ៥% | - | - | - | អាចវាយតម្លៃនៅចុងឆ្នាំ | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ឃ៖ ភាគរយសាលារៀនមានបង្គន់អនាម័យ | | | | ១០០% | - | - | - | អាចវាយតម្លៃនៅចុងឆ្នាំ | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ង៖ ភាគរយសាលារៀនមានទឹកស្អាត | | | | ៨៥% | - | - | - | អាចវាយតម្លៃនៅចុងឆ្នាំ | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ច៖ ភាគរយសាលារៀនមានកន្លែងលាងសម្អាតដៃ | | | | ៨៥% | - | - | - | អាចវាយតម្លៃនៅចុងឆ្នាំ | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ឆ៖ ភាគរយសាលារៀនមានប្រអប់សង្គ្រោះបឋម | | | | ៤៥% | - | - | - | អាចវាយតម្លៃនៅចុងឆ្នាំ | |
| **ចង្កោមសកម្មភាពទី១.៥.១៖ ការលើកកម្ពស់សុខភាពសិក្សា** | 739.5 | 121.6 | 16.4% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ក៖ ចំនួនគរុសិស្ស គរុនិស្សិត មន្ត្រីតែងតាំងស៊ប់ និងនិស្សិតជាប់អាហារូបករណ៍បានពិនិត្យសុខភាព និងកាយសម្បទា | | | | ៦០០ នាក់ | ៨៨៥ នាក់ | 147.5% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ខ៖ ចំនួនគ្រឹះស្ថានសិក្សាចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សា | | | | ១០ រាជធានី ខេត្ត | ៧ រាជធានី ខេត្ត | 70.0% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.គ៖ ចំនួនមន្ត្រីបានចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបំប៉ន និងកិច្ចប្រជុំ ក្នុងនិងក្រៅប្រទេស | | | | ៧០០ នាក់ | ២៦៩ នាក់ | 38.4% | ↓ | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ឃ៖ ចំនួនសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព (ស.ភ.សិស្ស និងស.ភ.គ្រូ) បានបោះពុម្ពតាមកម្រិតថ្នាក់ | | | | ១ ៣៦០ ០០០ ក្បាល | ៧៩ ១៥២ ក្បាល | 5.8% | ↓ | | |
| **ចង្កោមសកម្មភាពទី១.៥.២៖ អភិវឌ្ឍស្ថាប័ននិងសមត្ថភាពមន្ត្រីសុខភាពសិក្សាគ្រប់លំដាប់ថ្នាក់** | **412.5** | **261.7** | **63.4%** | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.២.ក៖ ចំនួនមន្ត្រីសុខភាពសិក្សាថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ បានចូលរួមការអប់រំផ្សព្វផ្សាយអំពីការលើកកម្ពស់សុខភាពសិក្សា | | | | ៥០០ នាក់ | ១៣២០ នាក់ | 264.0% | ↑ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.២.ខ៖ ចំនួនសិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សា បានចូលរួមការអប់រំផ្សព្វផ្សាយការអប់រំសុខភាព និងប្រធានបទសុខភាពសាធារណៈ | | | | ២ ០០០ នាក់ | ២ ១៥៣ នាក់ | 107.6% | ↑ | | |
| **អនុកម្មវិធី១.៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស (នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ)** | 2,442.3 | 597.3 | 24.5% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.ក៖ ចំនួនវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស | | | | ១៩ សាលា | ១៩ សាលា | 100% | ↑ | | |
| **ចង្កោមសកម្មភាពទី១.៦.១៖ អភិវឌ្ឍការបណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត អប់រំតម្រង់ទិសវិជ្ជាជីវៈ និងប្រឹក្សាអាជីព** | 2,416.8 | 597.3 | 24.7% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.ក៖ ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | | | | ៤ ៨២២ នាក់ | ១ ២៣០ នាក់ | 25.5% | ↓ | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.ខ៖ ចំនួនសាលារៀនអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន | | | | ៨៣៣ សាលា | ៥៥០ សាលា | 66% | → | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.គ៖ ចំនួនគ្រឹះស្ថានមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឯកសារណែនាំស្តីពីការជ្រើសរើសប្រភេទថ្នាក់វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម ឬជំនាញបច្ចេកទេសវិជ្ជាជីវៈ | | | | ៩៨ សាលា | ៩៨ សាលា | 100% | ↑ | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **ចង្កោមសកម្មភាពទី១.៦.២៖ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ** | 25.5 | 0.0 | 0.0% | | | | | | |
| **អនុកម្មវិធី១.៧៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ)** | 8,139.5 | 7,434.9 | 91.3% | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.ក៖ ចំនួនគរុសិស្ស គរុនិស្សិតបានទទួលការបណ្តុះបណ្តាល នៅសាលាគរុកោសល្យ | | | | ៣ ០០០ នាក់ | - | - | | វាយតម្លៃនៅចុងឆ្នាំ | |
